លេខ ២៤ ខែ តុលា - វិច្ឆិកា - ធ្នូ ព. ស. ២៥០៩

# ពន្លឺពុទ្ធចក្រ

## ទស្សនាវដ្ដី ប្រចាំត្រីមាស

នៃ

## ពុទ្ធិកសមាគម - មជ្ឈមណ្ឌលកម្ពុជរដ្ឋ

# LA LUMIERE BOUDDHIQUE

## REVUE TRIMESTRIELLE

DE

## L'ASSOCIATION DES BOUDDHISTES

## CENTRE DU CAMBODGE

OCTOBRE - NOVEMBRE - DECEMBRE 1966

Nº 24

លេខ ២៤ ខែ តុលា - វិច្ឆិកា - ធ្នូ ព. ស. ២៥០៩

# ពន្លឺពុទ្ធចក្រ

## ទស្សនាវដ្ដី ប្រចាំត្រីមាស

នៃ

## ពុទ្ធិកសមាគម-មជ្ឈមណ្ឌលកម្ពុជរដ្ឋ

# LA LUMIERE BOUDDHIQUE

**REVUE TRIMESTRIELLE**

DE

**L'ASSOCIATION DES BOUDDHISTES**

**CENTRE DU CAMBODGE**

**OCTOBRE - NOVEMBRE - DECEMBRE 1966**

**N° 24**

ចាងហ្វាងនៃការផ្សាយ : រ៉ាយ - លូត

បណ្ណាធិការ : នង - លន់

ទីសំណាក់ការបណ្ដោះអាសន្ន : វត្តឧណ្ណាលោម ភ្នំពេញ

**Directeur de publication : RAY - LOMUTH**

**Gérant : NONG - LONN**

**Siège provisoire : Watt Unnalom Phnom-Penh**

**— CAMBODGE —**

# ពន្លឺពុទ្ធចក្រ លេខ ២៤

| អត្ថបទ | មាតិការឿង | ទំព័រ |
|---|---|---|


១– សេចក្ដីអំពាវនាវរបស់គណៈកម្មាធិការនាយក រ៉ាយ-ល្មុត . . . . . . . . . . . . . . . . ១

២– បារមីកថា របស់សហជីវិន ឈឹម - ស៊ុម . . . . . . . . . . . . . . . . . . . . ៦

៣– អំពីបុណ្យព្រះបរមសព សម្ដេចព្រះសង្ឃរាជថ្នាក់ទី ២ . . . . . . . . . . . . . . . ១៥

៤– ព្រះពុទ្ធសាសនា ការល្បងពិចារណាឲ្យយល់ជាក់ រៀបរៀងដោយ
សម្ដេចក្រុមព្រះ ស៊ីសុវត្ថិ-មុនីរ៉េត . . . . . . . ២៩

៥– ពិធីសម្ពោធបញ្ចុះខ័ណ្ឌសីមា វត្តជោតញាណ និងវត្តឥន្ទញាណ ក្រុងព្រះសីហនុ . . . ៤៧

៦– វរប្បសិទ្ធិគាថា តែងដោយសម្ដេចព្រះសង្ឃរាជថ្នាក់ទី ១ . . . . . . . . . . . . . ៥៥

# សេចក្តីអំពាវនាវ

— ដោយហេតុថា ៖ បទបញ្ញត្តិមាត្រា ៨ នៃរដ្ឋធម្មនុញ្ញខ្មែរយើង មានចែងជាអាទិ៍ថា ៖

"សេរីភាពខាងជំនឿត្រូវបើកឲ្យមានដោយបរិបូណ៌ ។ សេរីភាពក្នុងការប្រតិបត្តិខាងផ្លូវសាសនា ក៏ត្រូវបើកឲ្យមានដូច្នោះដែរ... ។ ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ" ។

បទបញ្ញត្តិខាងលើនេះបានសេចក្តីថា ខេមរជនមានសេរីភាពខាងការគិត, ការពិចារណា ហើយជឿសាសនាណាបានតាមចិត្ត, ចង់កាន់សាសនាណា, ចង់ចេញពីសាសនាណាបានតាមចិត្ត ។ មិនតែប៉ុណ្ណោះ ខេមរជន មានសេរីភាពដាក់ទុកសព (រូបបុគ្គលស្លាប់) ដោយបូជាភ្លើងក្តី ដោយកប់ក្នុងធរណីក្តី ដោយចាត់តាមរបៀបអ្វីផ្សេងទៀតក្តី បានតាមចិត្ត ថែមទាំងចង់ធ្វើវត្តប្រតិបត្តិចំពោះទេវតា, ព្រះឥន្ទ្រ, ព្រះព្រហ្ម, អារក្ស, អ្នកតា, មេមត់, ធាតុខ្មោច, ដើមឈើ, ដំបូក, សត្វ....។ល។ បានតាមចិត្តផងដែរ ស្រេចហើយតែខ្លួនជឿ ។

បទបញ្ញត្តិរដ្ឋធម្មនុញ្ញខាងលើនេះ ស្របគ្នាទៅនឹងបទបញ្ញត្តិរបស់សេចក្តីថ្លែងជាសាកល នូវសិទ្ធិរបស់មនុស្សនៃសហប្រជាជាតិ នាក្រុងប៉ារីស ចុះថ្ងៃទី ១០ ធ្នូ គ.ស. ១៩៤៨ ដែលកម្ពុជាយើងបានចុះហត្ថលេខាផងដែរ មានសេចក្តីជាអាទិ៍ថា ៖

បុគ្គលនីមួយ ៗ មានសិទ្ធិត្រូវមានសេរីភាពខាងការគិត, ការជឿនិងការកាន់សាសនា; សិទ្ធិនេះជាហេតុបើកឲ្យមនុស្សមានសេរីភាពខាងការផ្លាស់ប្តូរសាសនា, ការផ្លាស់ប្តូរនូវសទ្ធាជ្រះថ្លារបស់ខ្លួន ព្រមទាំងសេរីភាពខាងការសំដែង លើកលាតត្រដាងនូវសាសនា និងសទ្ធាជ្រះថ្លារបស់ខ្លួនផង ដោយខ្លួនម្នាក់ឯង ឬដោយនៅរួបរួមជាមួយនឹងគេ ធ្វើកិច្ចជាសាធារណៈក្តី ជាឯកជនក្តី ធ្វើការបង្ហាត់បង្រៀនក្តី ធ្វើវត្តប្រតិបត្តិក្តី នៅក្នុងសាសនា និងនៅក្នុងការចាត់ចែងធ្វើពិធីទាំងពួង..... ។

សេចក្តីខាងលើនេះមានន័យថា ខេមរជនក្តី ជនបរទេសក្តី ដែលឋិតនៅក្នុងកម្ពុជរដ្ឋ មានសេរីភាពខាងជំនឿយ៉ាងទូលំទូលាយ.....ហើយមាត្រា ៨ នៃរដ្ឋធម្មនុញ្ញបញ្ជាក់ថា ៖

.....បើនឹងបន្ថយ (សេរីភាពខាងជំនឿ) ខ្វះបាន តែត្រង់ណាដែលវៀរពុំបាន ដើម្បីកុំឲ្យខូចសេចក្តីស្ងប់រៀបរយដល់មហាជន ។

សេចក្តីខាងលើនេះមានន័យម្យ៉ាងទៀតថា ការប្រាស្រ័យទាក់ទងកម្ពុជា ទៅនឹងពិភពលោកនាបច្ចុប្បន្នកាល បើកឲ្យវិជ្ជាគ្រប់បែបយ៉ាង ទាំងខាងផ្លូវកុសល ទាំងខាងផ្លូវអកុសល ហូរចូលមកកម្ពុជា ឬហូរចេញពីកម្ពុជាបានដោយសេរី ។

—ដោយហេតុថា ៖ ព្រះពុទ្ធសាសនានៅកម្ពុជរដ្ឋយើងសព្វថ្ងៃរស់រានមានជីវិត ដោយតាំងខ្លួននៅលើមូលដ្ឋានមាំមួន ពោលគឺព្រះបរិយត្តិធម៌និងព្រះនព្វលោកុត្តរធម៌ ថែមទាំងរដ្ឋធម្មនុញ្ញយើងបានទុកព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋក៏ពិតមែនហើយ តែមនោគមវិជ្ជា ឬ វិជ្ជាសាស្ត្រខាងគំនិតដែលហូរចូលមកកម្ពុជរដ្ឋយើង គឺសុទ្ធសឹងជាខាងផ្លូវលោកទាំងអស់ ម៉្លោះហើយក៏តែងញាំងសេចក្ដីជ្រះថ្លានៃខេមរជនក្នុងព្រះពុទ្ធសាសនា ឲ្យទន់ខ្សោយ ទ្រេតទ្រោតជាលំដាប់ ហើយងាករេទៅរកពយត្រេកត្រអាលធ្វើដំណើរទៅរកវត្ថុខាងផ្លូវលោកឈ្មោះថា អ៊ួមយន៎ះ!...ដែលមិនអាចនឹងសំរេចបាន។

## អាស្រ័យហេតុនេះ

យើងជាពុទ្ធសាសនិកខ្មែរ យើងមានសេចក្ដីថប់ព្រួយបារម្ភជានិច្ច ចំពោះវាសនានៃព្រះពុទ្ធសាសនានៅកម្ពុជរដ្ឋ, ព្រោះហេតុនោះបានជា នៅក្រោមព្រះបរមរាជូបត្ថម្ភនៃសម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជថ្នាក់ទី ១ នៃគណៈមហានិកាយ ព្រះបរមនាម **ជួន-ណាត** ជោតញ្ញាណោ ។

ពុទ្ធិកសមាគម-មជ្ឈមណ្ឌលកម្ពុជរដ្ឋ បានត្រូវបង្កើតឡើងក្នុង គ.ស. ១៩៥២ ដើម្បីប្រមូលកម្លាំងគ្នាធ្វើចលនាទប់ទល់ នឹងចរន្តនៃគំនិតអកុសលគ្រប់បែប-យ៉ាង ដែលមាននិន្នាការនាំឲ្យព្រះបរមពុទ្ធោវាទសៅហ្មង ។

នៅក្រោមព្រះបរមរាជូបត្ថម្ភ និងព្រះបរមរាជាធិបតិភាពនៃសម្ដេចព្រះមហាក្សត្រិយាណី បរមបពិត្រជាអម្ចាស់ជីវិត និងសម្ដេចព្រះប្រមុខរដ្ឋ, ពុទ្ធិកសមាគម-មជ្ឈមណ្ឌលកម្ពុជរដ្ឋ ក្នុងកំឡុងពេល ១៤ ឆ្នាំហើយ បានប្រតិបត្តិការបំពេញកុសលជាច្រើន ទៅតាមគោលបំណង និងកម្មវត្ថុរបស់ខ្លួន ពោលគឺ

ក) ឧបត្ថម្ភពួកសមាជិក ក្នុងការយកចិត្តទុកដាក់ធ្វើតាម និងក្នុងការប្រតិបត្តិត្រឹមត្រូវតាមពុទ្ធោវាទ;

ខ) រ៉ាប់រងធ្វើឲ្យមានឯកភាព, សាមគ្គីភាព និងភាតរភាព រវាងពុទ្ធមាមកជន;

គ) ផ្សាយនូវ អនុត្តរធម៌របស់ព្រះសម្ពុទ្ធ;

ឃ) ចាត់ចែងធ្វើសកម្មភាពខាងប្រជាសង្គ្រោះ, ការសិក្សា, វប្បធម៌ និងកិច្ចការដទៃទៀតជាមនុស្សធម៌;

ង) ខំប្រឹងធ្វើការពារ ឲ្យមានសន្តិភាព និងសុខដុម រវាងមនុស្សជាតិ . . . ;

ប) . . . សង្គ្រោះដល់វរជន ដែលចង់ទៅបំពេញវិជ្ជាខាងព្រះពុទ្ធសាសនា ឯប្រទេសក្រៅ ។

ក្នុងកំឡុងពេល ១៤ ឆ្នាំនេះ ដើម្បីជាគ្រឿងលើកទឹកចិត្តនៃសមាគមយើង, រាជរដ្ឋាភិបាលបាន ទទួលស្គាល់ ពុ.ម.ក. ថា ជាសមាគមមានប្រយោជន៍សាធារណៈ ដោយព្រះរាជក្រឹត្យលេខ ២២៤ ក.ប.រ.ន. ចុះថ្ងៃទី ៣ មិថុនា គ.ស. ១៩៦០ ថែមទាំងបានជួយមកសមាគមនេះ នូវឧបត្ថម្ភធនចំនួន ១០០.០០០ រៀល សំរាប់ឆ្នាំ ១៩៦២ ហើយ ៥០.០០០ រៀល ជារៀងរាល់ឆ្នាំតមក រហូតដល់សព្វថ្ងៃនេះ ។

ទោះបីរាជរដ្ឋាភិបាល, ទាយកទាយិកា, ព្រះភិក្ខុសង្ឃខ្លះបានជួយ ពុ.ម.ក. យ៉ាងណាក៏ដោយ, ទោះបីនៅកម្ពុជរដ្ឋយើង ព្រះពុទ្ធសាសនាតាំងលើមូលដ្ឋានមាំមួនយ៉ាងណាក៏ដោយ ក្នុងកំឡុងពេល ១៤ ឆ្នាំនេះ យើងបានទទួលការពិសោធន៍ច្រើន ដែលនាំឲ្យយើងសន្និដ្ឋានបានថា បើគ្មានព្រះភិក្ខុសង្ឃ នៅគ្រប់ទិសទីក្នុងព្រះរាជាណាចក្រជួយឧបត្ថម្ភផងទេ ចលនាយើងនឹងធ្វើដំណើរទៅកាន់សេចក្តីចំរើន ពុំបានលឿនឡើយ ។

ដូច្នេះ គណៈកម្មាធិការនាយកនៃ ពុ.ម.ក. ប្រចាំឆ្នាំ ១៩៦៦ អំពាវនាវសូមព្រះតេជព្រះគុណ មេគណ, អនុគណគ្រប់ស្រុក-ខេត្ត ហើយនិងព្រះភិក្ខុសង្ឃទាំងឡាយក្នុងកម្ពុជរដ្ឋ មេត្តាលៃលក និមន្ត ចូលរួបរួមនឹង ពុ.ម.ក. ដោយចុះនាមសមាជិកប្រភេទណាមួយនៃអង្គការដ៏ប្រសើរនេះ ។ មិនតែប៉ុណ្ណោះ, សូមព្រះតេជព្រះគុណមេគណ-អនុគណជាដើម មេត្តាជួយខ្វល់ខ្វាយធ្វើជាអ្នកផ្តួច-ផ្តើមគំនិតបង្កើតសាខានៃ ពុ.ម.ក. ពោលគឺគណៈកម្មាធិការខេត្ត-ស្រុក ឬសង្កាត់ ។

ឯទស្សនាវដ្តី "ពន្លឺពុទ្ធចក្រ" ទៀត ក៏គប្បីគ្រប់វត្តក្នុងកម្ពុជរដ្ឋ ជាវទៅតំកល់ទុកក្នុងបណ្ណាល័យ សំរាប់ជាគ្រឿងសតិប្រាជ្ញានៃភិក្ខុសាមណេរ និងពុទ្ធបរិស័ទជើងវត្តនោះៗ ។

អំពីការបង្កើតគណៈកម្មាធិការខេត្ត-ស្រុក ឬ សង្កាត់នោះ សូមប្រតិបត្តិតាមរបៀបជាគោលៗ ខាងក្រោមនេះ ៖

ជាដំបូង សូមព្រះតេជព្រះគុណមេគណ ឬអនុគណ ឬក៏ចៅអធិការ មេត្តាផ្តួចផ្តើមគំនិត ដោយ ពន្យល់ពុទ្ធបរិស័ទ នៅទីនោះៗ ឲ្យយល់ច្បាស់នូវប្រយោជន៍របស់ ពុ.ម.ក. ដូចមានរាយរាប់ជា គោលៗខាងលើស្រាប់ ។ បន្ទាប់តមក សូមឲ្យណាត់កាលបរិច្ឆេទនៃការជួបជុំគ្នា នៅទីណាមួយ

មាននៅទីវត្តជាដើម; លុះសាធុជនបាននិមន្ត-អញ្ជើញមកជួបជុំហើយ អ្នកផ្ដើមគំនិតគប្បីថ្លែងការប្រាស្រ័យតាមគួរ ស្រេចហើយប្រកាសសុំសន្និបាត សម្រុះសម្រួលបង្កើតក្រុមអភិបាលបណ្ដោះអាសន្នមួយ ប្រកបដោយសមាសភាពដូចតទៅនេះ ៖

បព្វជិត ឬឧបាសក ឬក៏ឧបាសិកា ដែលចាស់ជាងគេ ១ រូប ធ្វើជាប្រធាន,

— ដ — (ស្រេចហើយតែសន្និបាតជ្រើស) ១ រូប ធ្វើជាលេខាធិការ,

— ដ — — ដ — ២ រូប ឲ្យធ្វើជាអ្នកជំនួយ ។

ក្រុមអភិបាលបណ្ដោះអាសន្ននេះ ត្រូវចាត់ការបោះឆ្នោតជ្រើសតាំងសមាជិកនៃគណៈកម្មាធិការ (ខេត្ត ឬស្រុក ឬក៏សង្កាត់ តាមលក្ខណៈនៃសន្និបាត) ដោយសរសេរលើក្ដារខៀន នូវនាមបេក្ខជន ជាបព្វជិតក្ដី ជាឧបាសកក្ដី ជាឧបាសិកាក្ដី ។ ស្រេចហើយត្រូវចាត់ការចែកសន្លឹកឆ្នោត (ជាក្រដាសសតាមបាន) ជូនទីប្រជុំ ។ អ្នកបោះឆ្នោតត្រូវសរសេរលើសន្លឹកឆ្នោត នូវនាមបេក្ខជនចំនួនដប់ (១០) ដែលខ្លួនស្រឡាញ់ទុកចិត្ត ហើយនាំយកទៅដាក់ក្នុងហិប ដែលតំកល់ទុកប្រចាំការនេះ ។

ក្រោយដែលបានសួរបញ្ជាក់ ហើយឃើញថា គ្មានអ្នកបោះឆ្នោតទៀតទេ, ប្រធានក្រុមអភិបាលបណ្ដោះអាសន្ន ចាត់ការឲ្យបើកហិបរាប់ចំនួនសន្លឹកឆ្នោត ដោយប្រើវិធីណាមួយ ដែលយល់ឃើញថាស្រួល ។

ក្នុងបណ្ដាបេក្ខជន ដែលបានឆ្នោតច្រើនជាងគេនោះ ប្រធានត្រូវប្រកាសនាមចំនួនដប់(១០)ថាបានទទួលជ្រើសតាំងជាសមាជិកនៃគណៈកម្មាធិការ (ខេត្ត ឬស្រុក ឬក៏សង្កាត់) ហើយ ហើយត្រូវហៅអ្នកជាប់ឆ្នោតទាំងប៉ុន្មាននោះ ឲ្យនិមន្ត-អញ្ជើញមកបង្ហាញខ្លួន ចំពោះសន្និបាត ។ បន្ទាប់តមកប្រធានប្រកាសថា «បើស្ដីតាមគោលការណ៍» អ្នកជាប់ឆ្នោតទាំងដប់(១០)រូបនេះ ត្រូវប្រជុំគ្នាក្នុងសម្រុះសម្រួលគ្នាកំណត់នូវសមាសភាពនៃគណៈកម្មាធិការ ហើយជំរាបសន្និបាត អំពីសមាសភាពនេះក្នុងពេលប្រជុំនេះគឺ ៖

នាយគណៈកម្មាធិការ ១ រូប,

លេខាធិការ ១ រូប,

ហេរញ្ញិក ១ រូប,

ស្នងការ ៧ រូប,

« តែបើកាលៈទេសៈមិនអនុញ្ញាត ឲ្យធ្វើដូច្នេះបានភ្លាមទេនោះ សូមបេក្ខជនអ្នកជាប់ឆ្នោតម្នាក់ប្រកាសជំរាបសន្និបាតថា សមាសភាពនេះ នឹងផ្សាយក្នុងកំឡុងពេលប្រាំពីរ (៧) ថ្ងៃ ដោយសេចក្ដីជូនដំណឹងបិទនៅកន្លែង ដែលធ្វើសន្និបាតនេះជាដើម ។ ក្នុងកំឡុងពេល ៧ ថ្ងៃនេះ ត្រូវឲ្យអ្នកដែលជាប់ឆ្នោតមួយរូប ឬច្រើនរូបផ្ដើមគំនិតនិមន្ត-អញ្ជើញអ្នកជាប់ឆ្នោតទាំងអស់មកជួបជុំ រៀបចំសមាស-ភាពនៃគណៈកម្មាធិការ ដូចចែងខាងលើនេះស្រាប់ ដោយការសម្រុះសម្រួលគ្នាក្ដី ដោយការបោះឆ្នោតសម្ងាត់ក្ដី តាមការលៃលក » ។

អំពីកិច្ចការបង្កើតគណៈកម្មាធិការនេះ ត្រូវធ្វើកំណត់ហេតុជាពីរច្បាប់ បញ្ជូនទៅគណៈកម្មាធិការនាយកនាក្រុងភ្នំពេញ (ទីស្នាក់ការបណ្ដោះអាសន្ននៅវត្តឧណ្ណាលោម) ។ គណៈកម្មាធិការនាយក, ក្រោយការឲ្យសេចក្ដីយល់ព្រម ត្រូវត្រឡប់កំណត់ហេតុមួយច្បាប់មកគណៈកម្មាធិការខេត្ត ឬស្រុក ឬឃុំសង្កាត់នោះៗវិញ ទុកជាឯកសារតទៅ ព្រមទាំងប្រដាប់ប្រដាសព្វគ្រប់សំរាប់គណៈកម្មាធិការប្រើការ ។

គណៈកម្មាធិការដែលកើតឡើងជាដំបូង ដូចរៀបរាប់ខាងលើ ត្រូវបានឈ្មោះថា គណៈកម្មាធិការបណ្ដោះអាសន្នដែលមានអាយុមួយឆ្នាំ គិតពីថ្ងៃបោះឆ្នោតមក ។ ចាប់ពីដើមឆ្នាំទី ២ ហើយនៅរៀងរាល់ដើមឆ្នាំតទៅ គណៈកម្មាធិការខេត្ត ឬស្រុក ឬឃុំសង្កាត់ ត្រូវចាត់ការធ្វើមហាសន្និបាត ទៅតាមទម្រង់ដូចមានចែងពីប្រការ ២៩ ទៅ ៣៨ នៃលក្ខន្តិកៈ ពុ.ម.ក.ស្រាប់ ។

គណៈកម្មាធិការបណ្ដោះអាសន្ន ឬពេញទីនៃខេត្ត ឬស្រុក ឬឃុំសង្កាត់ ត្រូវទទួលភារៈចាត់ដំណើរការណ៍របស់ខ្លួន ឲ្យបានត្រឹមត្រូវទៅតាមបទបញ្ញត្តិលក្ខន្តិកៈ និងបទបញ្ជានៃ ពុ.ម.ក.តទៅ ។

គណៈកម្មាធិការនាយកនៃ ពុ.ម.ក. ប្រចាំឆ្នាំ ១៩៦៦ មានសេចក្ដីសង្ឃឹមមាំថា ព្រះតេជព្រះគុណមេគណ, អនុគណជាដើម ក្នុងព្រះរាជាណាចក្រ នឹងខ្វល់ខ្វាយជួយផ្ដើមគំនិតបង្កើតសាខានៃ ពុ.ម.ក. ឲ្យបានចំនួនច្រើន ដើម្បីយើងពុទ្ធមាមកជនទាំងព្រះរាជាណាចក្របានកាន់ដៃគ្នាការពារព្រះពុទ្ធសាសនាដែលជាគ្រឿងសំរាប់រម្ងាប់បង់ នូវភ្លើងទុក្ខភ្លើងកិលេសដ៏ពិត ៗ ។

ធ្វើនៅភ្នំពេញ, ចុះថ្ងៃទី ១៥ ធ្នូ គ.ស. ១៩៦៦

ប្រធានគណៈកម្មាធិការនាយក នៃ ពុ.ម.ក. ប្រចាំឆ្នាំ ១៩៦៦

ហត្ថលេខា : រ៉ាយ ល្មុត

# បារមីកថា

របស់បណ្ឌិតមហា ឈឹម-ស៊ុម អតីតសាស្ត្រាចារ្យ

ពាក្យថា **បារមី** ជាភាសាបាលី ប្រែថា : បដិបទាជាគ្រឿងដល់នូវត្រើយនៃពោធិសត្វ, សេចក្តីប្រតិបត្តិជាដំណើរទៅកាន់ព្រះនិព្វាន, ធម្មជាតិជាគ្រឿងឆ្លងទៅកាន់ត្រើយ ឬថាគុណសម្បត្តិដូចជានាវាសម្រាប់ពោធិសត្វចម្លងគ្នាទៅកាន់ត្រើយនាយ គឺព្រះនិព្វាន ។

**អធិប្បាយ :** សត្វលោកទាំងអស់ទោះជាមនុស្សក្តី ជាតិរច្ឆានក្តី ជាទេវតាក្តី សុទ្ធតែជាអ្នកលិចលង់ក្នុងសមុទ្រ គឺវាលវដ្តសង្សារ គឺថាលិចនៅក្នុងជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ ក្នុងការវេទនាលំបាក ព្រោះការកើត ការចាស់ ការឈឺ ការស្លាប់, ស្លាប់ហើយកើតទៀត ចាស់ទៀតឈឺទៀតស្លាប់ទៀត ឆ្លងអំពីវាលវដ្តសង្សារដែលដូចជាមហាសមុទ្រប្រកបដោយគ្រោះថ្នាក់ច្រើនបំផុត គឺសេចក្តីទុក្ខលំបាកទាំងនេះពុំរួច ព្រោះមានបារមីពុំគ្រប់គ្រាន់ ពុំទាន់ចាស់ក្លា ។

ព្រះពោធិសត្វទាំងឡាយខ្លាចភ័យ ក្នុងវដ្តសង្សារនេះណាស់ ទើបទ្រង់ស្វែងរកនូវធម្មជាតិសម្រាប់ចម្លងខ្លួនទៅកាន់ព្រះនិព្វាន ដែលជាត្រើយនៃវដ្តសង្សារ ។ ធម្មជាតិសម្រាប់ចម្លងខ្លួនទៅកាន់ត្រើយ គឺព្រះនិព្វាននេះឯង ដែលហៅថា បារមី ។ ខែបំភ្លឺសេចក្តីថា : ជាតិ ជរា ព្យាធិ មរណៈ ជាកងទុក្ខយ៉ាងធំ ដែលសត្វនិករឆ្លងពុំរួច, នេះឈ្មោះថា វាលវដ្តសង្សារ ។ ត្រើយម្ខាងខាងនាយ ដែលអ្នកណាមួយឆ្លងផុតវាលវដ្តសង្សារហើយដល់, នោះឈ្មោះ ថាព្រះនិព្វាន ។ ធម្មជាតិដែលដូចជានាវាសម្រាប់អ្នកមានប្រាជ្ញាជិះឆ្លងវាលវដ្តសង្សារ ទៅកាន់ត្រើយនាយ គឺព្រះនិព្វាន, នោះឈ្មោះថា បារមី ។

សរុបសេចក្តីថា : មិនត្រឹមតែពោធិសត្វទេ ដែលត្រូវបំពេញបារមី ប្រជាជនប្រុស-ស្រីដទៃ ៗ ដែលមានប្រាជ្ញាល្អចង់បានសេចក្តីសុខ សេចក្តីចំរើន ក៏ត្រូវតែបំពេញបារមីដែរ ។ ការបំពេញបារមីគឺសេចក្តីប្រព្រឹត្តល្អត្រឹមត្រូវតាមគន្លងច្បាប់ហ្នឹងឯង ។

## បារមីមាន ១០ ប្រការដោយសង្ខេបគឺ[១]

១- **ទាន** ការឲ្យឬអំណោយ, ការបរិច្ចាគ, ការលះនូវសេចក្តីកំណាញ់;

២- **សីល** ការរក្សាសីល, ការកាន់ត្រណម ដើម្បីសេចក្តីពបសានៃកាយ វាចា;

៣- **នេក្ខម្ម** ការចេញសាង (ផ្នួស), ការចេញចាកកាមគុណ;

៤- **បញ្ញា** ការស្គាល់ច្បាស់នូវកងសង្ខារ, ការដឹងច្បាស់នូវហេតុនិងផល;

---

១ ប្រែបំប្រួញចាកគម្ពីរជិនមហានិទាន ភាសាបាលី ។

**៥– វីរិយ** ការព្យាយាមក្នុងការលះនិងក្នុងការបំពេញ;

**៦– ខន្តិ** ការអត់ធន់, ការអត់ធ្មត់, ខន្តី;

**៧– សច្ច** ការទៀងទាត់ដោយកាយវាចាចិត្ត;

**៨– អធិដ្ឋាន** ការតាំងចិត្តស៊ប់ចំពោះករណីយកិច្ចណាមួយ[1];

**៩– មេត្តា** សេចក្ដីប្រណីដោយបំណងចង់ឲ្យបានសេចក្ដីសុខដូចគ្នាទៅ;

**១០– ឧបេក្ខា** ការតាំងខ្លួនតាំងចិត្តជាកណ្ដាលមិនស្អប់ពេក មិនស្រឡាញ់ពេក, ដំណើរមិនលំអៀងទៅខាងណាម្ខាង ៗ ។

បារមីទាំង ១០ នេះ ចែកចេញជាបី ៗ តទៅទៀតគឺ

១– បារមី (បារមីទាំង ១០ ជាន់ទាប)

២– ឧបបារមី (បារមីទាំង ១០ ជាន់កណ្ដាល)

៣– បរមត្ថបារមី (បារមីទាំង ១០ ជាន់ខ្ពស់) រួមត្រូវជាបារមី ៣០ ដោយពិស្ដារ ។

**អធិប្បាយ:** ការលះនូវប្រពន្ធកូននិងទ្រព្យផ្សេង ៗ មានស្រូវជាដើម របស់ខ្លួនឲ្យទៅជាទាន ហៅថា ទានបារមី ។ ការលះនូវរាងកាយ គឺអវយវៈតូចធំរបស់ខ្លួនឲ្យទៅជាទាន ហៅថា ទានឧបបារមី។ ការលះនូវជីវិតរបស់ខ្លួនឲ្យទៅជាទាន ហៅថា ទានបរមត្ថបារមី ។

ការរក្សាសីល មិនព្រមប្រព្រឹត្តកន្លងសិក្ខាបទ ឬបទបញ្ញត្តិ ព្រោះហេតុប្រពន្ធកូននិងទ្រព្យជាដើម ហៅថា សីលបារមី ។ ឧទាហរណ៍ដូចជាប្រពន្ធឬកូននៃបុគ្គលណា មានជម្ងឺត្រូវដល់នូវសេចក្ដីស្លាប់, ទោះបីពេទ្យត្រូវថា "ចូរសម្លាប់សត្វអ្វីមួយដើម្បីធ្វើជាថ្នាំ ទើបអ្នកជម្ងឺនោះផុតពីស្លាប់" ដូច្នេះក៏ដោយ បុគ្គលនោះក៏ពុំព្រមសម្លាប់ គឺសុខចិត្តឲ្យប្រពន្ធកូនស្លាប់ មិនសុខចិត្តសម្លាប់សត្វ ដើម្បីជួយជីវិតនៃប្រពន្ធកូនឡើយ ដូច្នេះជាដើម ហៅថា សីលបារមី ។ ការរក្សាសីលមិនព្រមប្រព្រឹត្តកន្លងសិក្ខាបទ ព្រោះហេតុនៃអវយវៈតូចធំរបស់ខ្លួន ហៅថា សីលឧបបារមី ។ ការរក្សាសីលមិនព្រមប្រព្រឹត្តកន្លងសិក្ខាបទ ព្រោះហេតុនៃជីវិតរបស់ខ្លួន ហៅថា សីលបរមត្ថបារមី ។

ការផ្ដាច់អាល័យក្នុងប្រពន្ធកូន និងទ្រព្យមានស្រូវជាដើម ហើយចេញសាង ហៅថា នេក្ខម្មបារមី។ ការផ្ដាច់អាល័យឥតស្ដាយអវយវៈតូចធំរបស់ខ្លួន ហើយចេញសាង ហៅថា នេក្ខម្មឧបបារមី ។

---

១ ការតាំងចិត្តស៊ប់ឬងសង្រួង ក៏ហៅថា អធិដ្ឋានដែរ ។

ការផ្ដាច់អាល័យឥតស្ដាយជីវិតរបស់ខ្លួនហើយចេញសាង ហៅថា នេក្ខម្មបរមត្ថបារមី ។

ការដកឡើងនូវតណ្ហា (សេចក្ដីប្រាថ្នា) ផុតអំពីគ្រឿងឧបករណ៍ គឺកូនប្រពន្ធទ្រព្យធនរបស់ខ្លួន ហើយធ្វើនូវការវិនិច្ឆ័យ ចំពោះប្រយោជន៍និងមិនមែនប្រយោជន៍ដល់សត្វទាំងឡាយ តាមការពិត ហៅថា បញ្ញាបារមី ។ ការដកឡើងនូវសេចក្ដីប្រាថ្នាផុតអំពីអវយវៈតូចធំរបស់ខ្លួន ហើយធ្វើនូវការវិនិច្ឆ័យ . . . ហៅថា បញ្ញាឧបបារមី ។ ការដកឡើងនូវសេចក្ដីប្រាថ្នាផុតអំពីជីវិតរបស់ខ្លួន ហើយធ្វើនូវការវិនិច្ឆ័យ . . . ហៅថា បញ្ញាបរមត្ថបារមី[១] ជាអាទិ៍ ។

សេចក្ដីព្យាយាម ដើម្បីបំពេញនូវបារមីទាំងឡាយ មានប្រភេទដូចដែលពោលមកហើយក្ដី ដើម្បីបំពេញនូវកុសលផ្សេង ៗ ក្ដី ដើម្បីលះអកុសលផ្សេង ៗ ក្ដី ពុំព្រមបន្ធូរបន្ថយ ព្រោះហេតុនៃគ្រឿងឧបករណ៍ មានកូនប្រពន្ធទ្រព្យធនជាដើមរបស់ខ្លួន ហៅថា វីរិយបារមី ។ . . . ពុំព្រមបន្ធូរបន្ថយ ព្រោះហេតុនៃអវយវៈតូចធំរបស់ខ្លួន ហៅថា វីរិយឧបបារមី ។ . . . ពុំព្រមបន្ធូរបន្ថយ ព្រោះហេតុនៃជីវិតរបស់ខ្លួន ហៅថា វីរិយបរមត្ថបារមី ។

ការអត់ទ្រាំ ការទប់ចិត្តពុំព្រមតបតចំពោះជនអ្នកធ្វើនូវសេចក្ដីអន្តរាយដល់គ្រឿងឧបករណ៍ គឺកូនប្រពន្ធទ្រព្យធនរបស់ខ្លួន ហៅថា ខន្តិបារមី ។ . . . ចំពោះជនអ្នកធ្វើនូវសេចក្ដីអន្តរាយដល់អវយវៈតូចធំរបស់ខ្លួន ហៅថា ខន្តិឧបបារមី ។ . . . ចំពោះជនអ្នកធ្វើនូវសេចក្ដីអន្តរាយដល់ជីវិតរបស់ខ្លួន ហៅថា ខន្តិបរមត្ថបារមី ។ (ការអត់ធន់តបតនឹងរដូវ មានក្ដៅនិងត្រជាក់ជាដើម ក៏ហៅថា ខន្តីដែរ) ។

ការមិនលះបង់នូវកិរិយាពិតប្រាកដ (ដោយកាយវាចាចិត្ត) ព្រោះហេតុនៃគ្រឿងឧបករណ៍របស់ខ្លួន ហៅថា សច្ចបារមី ។ . . . ព្រោះហេតុនៃអវយវៈតូចធំរបស់ខ្លួន ហៅថា សច្ចឧបបារមី ។ . . . ព្រោះហេតុនៃជីវិតរបស់ខ្លួន ហៅថា សច្ចបរមត្ថបារមី ។

ការតាំងចិត្តស៊ប់សង្កត់លើបារមីទាំង ៩ មិនព្រមរេរុះ ព្រោះហេតុនៃគ្រឿងឧបករណ៍របស់ខ្លួន ហៅថា អធិដ្ឋានបារមី[២] ។ . . . ព្រោះហេតុនៃអវយវៈតូចធំរបស់ខ្លួន ហៅថា អធិដ្ឋានឧបបារមី ។

---

១ ក្នុងចរិយាបិដក មានព្រះពុទ្ធភាសិតថា តថាគតពិចារណាដោយប្រាជ្ញា បានដោះនូវព្រាហ្មណ៍ចាកសេចក្ដីទុក្ខ (ឲ្យរួចពីសេចក្ដីស្លាប់ ព្រោះសត្វពស់នៅក្នុងថង់ (ថង់) របស់ខ្លួនចឹក), ឥតមានសភាវៈដទៃស្មើដោយប្រាជ្ញាទេ, នេះជាបញ្ញាបារមីរបស់តថាគត ។ ក្នុងគម្ពីរអដ្ឋសាលិនី ពន្យល់សេចក្ដីនៃពុទ្ធភាសិតនោះថា : បញ្ញាបារមីនៃសេនកបណ្ឌិត កាលបង្ហាញនូវពស់ដែលនៅក្នុងថង់ព្រាហ្មណ៍ (ឲ្យព្រាហ្មណ៍រួចចាកសេចក្ដីស្លាប់) នោះឈ្មោះថា បញ្ញាបរមត្ថបារមី ។ តាមន័យក្នុងអដ្ឋកថានេះ យើងអាចយល់ថា : ការប្រើប្រាជ្ញាវិនិច្ឆ័យ តាមការពិត មិនមែនត្រឹមតែបូជាជីវិតរបស់ខ្លួនទេ, សូម្បីការប្រើប្រាជ្ញាក្នុងការដោះជីវិតគេ ក៏ឈ្មោះថា បញ្ញាបរមត្ថបារមីដែរ ។ ២ ក្នុងគម្ពីរជាតកដ្ឋកថា ឯកនិបាតវណ្ណនា បញ្ជាក់ថា : ទានបារមី អធិដ្ឋាសិ ។ល។ ឧបេក្ខាបារមី អធិដ្ឋាសិ = ពោធិសត្វទ្រង់អធិដ្ឋាននូវទានបារមី ។ល។ ទ្រង់អធិដ្ឋាននូវឧបេក្ខាបារមី ។ បានសេចក្ដីថា : ក្នុងបារមីមួយ ៗ សុទ្ធតែមានអធិដ្ឋានបារមីសង្កត់លើជាដរាប ។

... ព្រោះហេតុនៃជីវិតរបស់ខ្លួន ហៅថា អធិដ្ឋានបរមត្ថបារមី ។

មួយទៀត ការតាំងចិត្តប្រាថ្នាសំបូងសង្រ្គែងក្នុងគ្រាវិនាសនូវគ្រឿងឧបករណ៍ ឬអវយវៈតូចធំ ឬជីវិតរបស់ខ្លួន ដោយការអាងដល់បារមីមានទានជាដើម ដែលខ្លួនបានបំពេញហើយ ដើម្បីព្រះនិព្វានតែម្យ៉ាង, ដូច្នេះក៏ហៅថា អធិដ្ឋានបារមីដែរ ។

ការមិនលះបង់នូវសេចក្ដីអាណិតមេត្តាចំពោះសត្វទាំងឡាយ ទោះបីជាអ្នកបៀតបៀននូវគ្រឿងឧបករណ៍របស់ខ្លួនក៏ដោយ ហៅថា មេត្តាបារមី ។... ចំពោះសត្វទាំងឡាយ ទោះបីជាអ្នកបៀត-បៀននូវជីវិតរបស់ខ្លួនក៏ដោយ ហៅថា មេត្តាបរមត្ថបារមី ។

ការបាននូវភាពនៃចិត្តជាកណ្ដាល ៗ (ពុំស្អប់ពេក ពុំស្រឡាញ់ពេក) ចំពោះសត្វនិងសង្ខារទាំង-ឡាយ អ្នកមានឧបការៈ និងមិនមានឧបការៈ ចំពោះគ្រឿងឧបករណ៍របស់ខ្លួន ហៅថា ឧបេក្ខាបារមី ។ ... ចំពោះអវយវៈតូចធំរបស់ខ្លួន ហៅថា ឧបេក្ខាឧបបារមី ។ ... ចំពោះជីវិតរបស់ខ្លួន ហៅថា ឧបេក្ខាបរមត្ថបារមី ។ គ្រប់បារមី ៣០ តែប៉ុណ្ណេះ ។

សរុបសេចក្ដីថា : បារមីទាំង ១០ ដែលពោធិសត្វបំពេញ ប្ដូរនឹងគ្រឿងឧបករណ៍មានកូនប្រពន្ធទ្រព្យធនជាដើមរបស់ខ្លួន ហៅថា បារមី ។ ប្ដូរនឹងអវយវៈតូចធំរបស់ខ្លួន ហៅថា ឧបបារមី ។ ប្ដូរនឹងជីវិតរបស់ខ្លួន ហៅថា បរមត្ថបារមី ។

## ការបំពេញបារមីក្នុងជាតិនីមួយ ៗ

ព្រះពោធិសត្វគ្រប់ព្រះអង្គតែងបំពេញបារមីទាំង ១០ ឬទាំង ៣០ នេះ រាល់ ៗ ព្រះជាតិ ប៉ុន្តែក្នុងព្រះជាតិខ្លះ បំពេញបារមី ៣ ក៏មាន ៤ ក៏មាន ក្នុងព្រះជាតិខ្លះ បំពេញបារមី ៥ ក៏មាន ៦ ក៏មាន, មានតែក្នុងព្រះជាតិជាព្រះវេស្សន្តរ ទើបទ្រង់បំពេញយ៉ាងបរិបូណ៌នូវបារមីគ្រប់ទាំង ១០ ដូចដែលលោកបានវែកញែកទុកក្នុងគម្ពីរជិនមហានិទានថា :

**ទានបារមី** នៃព្រះវេស្សន្តរ បណ្ឌិតគប្បីជ្រាបថា ក្នុងកាលដែលព្រះវេស្សន្តរនោះ មានព្រះបន្ទូលជាមួយនឹងព្រះមាតាថា "ខ្ញុំចង់ឲ្យទាន" ដូច្នេះ ក្នុងថ្ងៃដែលព្រះវេស្សន្តរទ្រង់ប្រសូតមកផង ក្នុងកាលដែលព្រះវេស្សន្តរមានព្រះជន្ម ៨ ឆ្នាំពីកំណើត ទ្រង់ព្រះរាជទាននូវគ្រឿងប្រដាប់អស់ភារៈ ៩ ផង ដល់មេដោះទាំងឡាយផង ក្នុងកាលដែលព្រះវេស្សន្តរបានរាជាភិសេកហើយ ទ្រង់ព្រះរាជទាននូវដំរីផង ក្នុងកាលនៃសត្តសតកមហាទានផង ក្នុងកាលដែលទ្រង់ព្រះរាជទាននូវព្រះរាជបុត្រ និង

ព្រះជាយាផង ក្នុងកាលដែលទ្រង់ព្រះរាជទាននូវរតន៍ ៧ ប្រការផង ។

**សីលបារមី** បណ្ឌិតគប្បីជ្រាបថា ក្នុងកាលដែលព្រះវេស្សន្តរទ្រង់ជាគ្រហស្ថនៅឡើយ ទ្រង់ធ្វើឧបោសថអស់កន្លះខែជាលំដាប់ផង ក្នុងកាលដែលទ្រង់ជាបព្វជិតផង ។

**នេក្ខម្មបារមី** បណ្ឌិតគប្បីជ្រាបថា ក្នុងកាលដែលព្រះវេស្សន្តរទ្រង់ចេញចាកព្រះនគរទៅគង់នៅក្នុងព្រៃទ្រង់ដកព្រះរាជហឫទ័យចេញផុតចាកកាមគុណ ។

**បញ្ញាបារមី** បណ្ឌិតគប្បីជ្រាបថា ក្នុងកាលដែលព្រះវេស្សន្តរទ្រង់គង់នៅក្នុងព្រៃទ្រង់បន្ទោបង់ដោយប្រាជ្ញាញាណ នូវសេចក្ដីសោករបស់ព្រះអង្គ ដែលកើតអំពីសេចក្ដីស្នេហាក្នុងបុត្តទាំងឡាយដែលព្រាហ្មណ៍កំពុងនាំទៅ ហើយទ្រង់គង់នៅស្ងៀមតាមប្រក្រតី ។

**វីរិយបារមី** បណ្ឌិតគប្បីជ្រាបថា ក្នុងកាលដែលព្រះវេស្សន្តរនោះ ទ្រង់ព្យាយាមទៅទតសាលាធទានរាល់តែកន្លះខែជាលំដាប់ផង ក្នុងកាលដែលព្រះវេស្សន្តរទ្រង់ព្រះផ្នួសហើយ ព្យាយាមក្នុងកិច្ចមានការបូជាភ្លើងជាដើម ដើម្បីសន្សំនូវតេជោកសិណផង ។

**ខន្តិបារមី** បណ្ឌិតគប្បីជ្រាបថា ក្នុងកាលទាំងឡាយមានកាលដែលទ្រង់ពុំញុំាងសេចក្ដីក្រោធឲ្យកើតឡើងចំពោះព្រះបិតា ដែលទ្រង់បំបរបង់ខ្លួនតាមពាក្យនៃអ្នកស្រីពិរាស្ត្រទាំងឡាយ ហើយទ្រង់មានព្រះរាជទុក្ការវួសកាយ មានព្រះភក្ត្រដ៏ប្រិមប្រិយ៍ដូចប្រក្រតីជាដើមផង ក្នុងកាលដែលទ្រង់ទប់ពុំឲ្យមានសេចក្ដីក្រោធ ចំពោះជូជកព្រាហ្មណ៍ ដែលប្រហារនូវព្រះរាជបុត្រទាំងឡាយរបស់ព្រះអង្គ ហើយនាំទៅផង ។

**សច្ចបារមី** បណ្ឌិតគប្បីជ្រាបថា ក្នុងកាលដែលព្រះអង្គមិនបញ្ឆោតព្រាហ្មណ៍ទាំងឡាយ ហើយទ្រង់ព្រះរាជទាននូវដំរីជាដើម តាមព្រះរាជបដិញ្ញាឥតល្អៀង ។

**អធិដ្ឋានបារមី** បណ្ឌិតគប្បីជ្រាបថា ក្នុងកាលដែលព្រះវេស្សន្តរទ្រង់ទតឃើញនូវសេនារបស់ខ្លួន ទ្រង់ខ្លាចសេចក្ដីស្លាប់ ទ្រង់ទប់ព្រះរាជហឫទ័យខ្ជាប់យ៉ាងមាំគង់ព្រងើយក្នុងបណ្ណសាលា ។

**មេត្តាបារមី** បណ្ឌិតគប្បីជ្រាបថា ក្នុងកាលដែលទ្រង់ព្រះរាជទាននូវដំរីជាដើម តាមអំណាចនៃសេចក្ដីមេត្តាដល់ពួកព្រាហ្មណ៍អ្នកកលិង្គរាស្ត្រទាំងឡាយផង ក្នុងកាលដែលព្រះវេស្សន្តរទ្រង់គង់នៅក្នុងព្រៃ ទ្រង់ផ្សាយនូវមេត្តាដល់ពួកសត្វម្រឹគទាំងឡាយជាដើមផង ។

**ឧបេក្ខាបារមី** បណ្ឌិតគប្បីជ្រាបថា ក្នុងកាលដែលព្រះវេស្សន្តរមិនទ្រង់ធ្វើនូវសេចក្ដីស្នេហា

ចំពោះបុគ្គលជាទីស្រឡាញ់ទាំងឡាយ ថែមទាំងមិនក្រោធចំពោះជូជកព្រាហ្មណ៍ ហើយទ្រង់គង់នៅដោយអាការជាកណ្ដាល (មិនស្អប់មិនស្រឡាញ់) ។

ព្រះពោធិសត្វនៃយើង កាលទ្រង់ជាព្រះវេស្សន្តរទ្រង់បានបំពេញនូវបារមីទាំង ១០ ក្នុងមួយព្រះជាតិយ៉ាងនេះ ។ ការវែកញែកដូច្នេះ បណ្ឌិតទាំងឡាយពីបុរាណ បានចារឹកទុកក្នុងគម្ពីរបាលីស្រាប់ ដើម្បីជាគំរូ ។ បើមានគំរូដូច្នេះហើយ សាស្ត្រាចារ្យទាំងឡាយជាន់ក្រោយមក ក៏គួរតែវែកញែកកើត នូវការបំពេញបារមីនៃព្រះពោធិសត្វទាំងឡាយ មានព្រះតេមិយ ឬព្រះមហោសថជាដើម ។

ការវែកញែកតាមគំរូខាងដើមនេះ លុះណាតែអ្នកសិក្សាជាន់ខ្ពស់ប្រកបដោយព្យាយាមច្រើន ទើបមិនតឹងគំនិត, បើអ្នកសិក្សាជាន់ទាប ពុំសូវមានឱកាសពុំសូវមានព្យាយាម ប្រហែលជាតឹងគំនិតទេដឹង? ហេតុដូច្នេះ បានជាអ្នកនិពន្ធជាន់ដើម នៅប្រទេសថៃ[1] បានសរសេររឿងទសជាតក៍ គឺជាតក ១០ ប្រកបផ្សំនឹងបារមី ១០ ថា ៈ

១– ព្រះតេមិយ បំពេញនេក្ខម្មបារមី,
២– ព្រះមហាជនក បំពេញវីរិយបារមី,
៣– ព្រះសុវណ្ណសាម បំពេញមេត្តាបារមី,
៤– ព្រះនេមិរាជ បំពេញអធិដ្ឋានបារមី,
៥– ព្រះមហោសថ បំពេញបញ្ញាបារមី,
៦– ព្រះភូរិទត្ត បំពេញសីលបារមី,
៧– ព្រះចន្ទកុមារ បំពេញខន្តិបារមី,
៨– ព្រះនារទព្រហ្ម បំពេញឧបេក្ខាបារមី,
៩– ព្រះពិធុរ បំពេញសច្ចបារមី,
១០– ព្រះវេស្សន្តរ បំពេញទានបារមី ។

ការប្រកបផ្សំផ្គូរគ្នា ១០ គម្រប់នឹង ១០ ដូច្នេះ ទោះបីពុំត្រឹមត្រូវតាមគម្ពីរក៏ដោយចុះ, ប៉ុន្តែជាការមួយដែលអ្នកសិក្សាជាន់ទាបក្នុងសម័យនេះ គួរអនុវត្តតាមបណ្ដោះអាសន្នដែរ ព្រោះជាការងាយយល់ ហើយទាំងធម្មកថិកអ្នកសំដែងធម៌ក្នុងស្រុកយើង ក៏ធ្លាប់សំដែងបែបនេះមកហើយផងដែរ ។ ប៉ុន្តែសូម

១ យើងស្រាវជ្រាវរកឈ្មោះអ្នកនិពន្ធបែបនេះឃើញដែរ, ប៉ុន្តែពុំទាន់បង្ហាញឈ្មោះក្នុងសៀវភៅនេះទេ ។

កុំភ្លេចថា "ពុំទាន់ត្រឹមត្រូវទេ" ដូច្នេះផងកុំខាន ។

មួយទៀត គួរអ្នកសិក្សាតាំងចិត្តថា បើអាត្មាអញសិក្សាដល់ថ្នាក់ខ្ពស់ឡើង ៗ គួរតែរាវរកសេចក្តីត្រូវក្នុងរឿងនេះកុំខាន ។

ខ្ញុំសូមចុចគោលគំនិតខ្លះទុកឲ្យគិតតទៅ :

១– គួរពិនិត្យមើលពាក្យប្រារព្ធខាងដើមជាតកនីមួយ ៗ ឲ្យឃើញថា ជាតកណាព្រះពុទ្ធទ្រង់ប្រារព្ធនូវបារមីណា ទើបទ្រង់សំដែងជាតកនោះឡើង ?

២– គួរពិនិត្យគម្ពីរចរិយាបិដកត្រង់រឿងព្រះចន្ទកុមារ នឹងឃើញថាព្រះចន្ទកុមារបំពេញខន្តិបារមីមែនឬ ? ឬថាបំពេញទានបារមីទៅវិញទេ ?

គម្ពីរទាំងនេះសុទ្ធតែជាគម្ពីរព្រះត្រៃបិដក ជាគោលដើមនៃជាតកទាំងនេះ ។ បើនិយាយដល់អដ្ឋកថារបស់គម្ពីរព្រះត្រៃបិដកទាំងនេះផង ឬដល់បករណ៍ពិសេស ដូចគម្ពីរជិនមហានិទានជាដើមផងនោះ មុខជានឹងឃើញដូចខ្ញុំថាពុំខាន ។

## បារមីកថាបរិយោសាន

បារមីកថា ខ្ញុំសរសេរដោយសង្ខេបប៉ុណ្ណេះចប់ ពី ព. ស. ២៥០៧ ។ ដល់ ព. ស. ២៥០៩ ខ្ញុំចាត់ការបោះពុម្ពដល់មកត្រឹមនេះ ស្រាប់តែបានទទួលឯកសារសំខាន់មួយ ដែលលោក និម-ណាវត្រី សាស្ត្រាចារ្យខ្មែរ ជាអ្នកសុទិដ្ឋិនិយម បានផ្តល់មកឲ្យខ្ញុំ ។ ឯកសារនោះ ឈ្មោះ "ទសជាតក" អក្សរភាសាសៀម ជាព្រះរាជនិពន្ធនៃព្រះចៅ ចរចឡ្យធើ ក្រុមហ្លួងជិនវរសិរិវឌ្ឍន៍ សម្តេចព្រះសង្ឃរាជជាម្ចាស់នៃប្រទេសសៀម ទ្រង់បានស្តាបនាឡើង ១០ ឆ្នាំ ទើបចប់ទាំង ១០ ជាតក គឺ ១ ឆ្នាំចប់តេមិយជាតក ទ្រង់ចាត់ឲ្យបោះពុម្ពចែក ក្នុង ព. ស. ២៤៧១ ក្នុងថ្ងៃទី ១៦ ខែធ្នូ ដែលជាថ្ងៃកំណើតរបស់ព្រះអង្គ ។ ទ្រង់ឲ្យបោះពុម្ពចែក ១ ឆ្នាំថែមជាតកមួយ ៗ ដល់ថ្ងៃទី ១៦ ធ្នូ ព. ស. ២៤៨១ ទ្រង់ចែកគ្រប់ជាតកទាំង ១០ ដែលរួមហៅថា ទសជាតក ។ ក្នុងឆ្នាំគម្រប់ ១០ ទ្រង់បាននិពន្ធពាក្យនាំ (អារម្ភកថា) ដែលខ្ញុំប្រែកាត់យកមួយកំណាត់មកបញ្ជាក់ក្នុងទីនេះ ដូចតទៅ : . . . . .

ទសជាតក៍នោះ ខ្ញុំធ្លាប់បានឮលោកអ្នកធំពោលថា ព្រះពោធិសត្វជាតិនោះ បំពេញបារមីយ៉ាងនោះ ដរាបដល់បានចុះជាបែបថា :

– ព្រះតេមិយពោធិសត្វ បំពេញខន្តិបារមី,
– ព្រះមហាជនកពោធិសត្វ បំពេញវីរិយបារមី,
– សុវណ្ណសាមពោធិសត្វ បំពេញសច្ចបារមី,
– ព្រះនេមិរាជពោធិសត្វ បំពេញនេក្ខម្មបារមី,
– មហោសថពោធិសត្វ បំពេញបញ្ញាបារមី,
– ភូរិទត្តនាគរាជពោធិសត្វ បំពេញសីលបារមី,

– ព្រះចន្ទកុមារពោធិសត្វ បំពេញអធិដ្ឋានបារមី,
– ព្រះនារទព្រហ្មពោធិសត្វ បំពេញមេត្តាបារមី,
– វិធុរបណ្ឌិតពោធិសត្វ បំពេញឧបេក្ខាបារមី,
– ព្រះវេស្សន្តរពោធិសត្វ បំពេញទានបារមី ។

ឬថាបារមីនោះ ៗ លោកទាញរឿងរបស់ពោធិសត្វឈ្មោះនោះ ៗ មកប្រៀបធៀបឲ្យឃើញជាឧទាហរណ៍ធ្វើឲ្យខ្ញុំចូលចិត្តមកអស់កាលជាអង្វែងហើយ ដោយមិនបានយកចិត្តពិចារណា ។ ដូច្នេះឃើញថាពោធិសត្វឈ្មោះមួយ បំពេញបារមីតែមួយប៉ុណ្ណោះអស់មួយជាតិ ។ កាលមកប្រែកន្សោមនេះទើបបានសេចក្ដីឃើញថ្មីថា : លោកពោលដូច្នោះសំដៅសេចក្ដីថា បារមីនេះ ព្រះពោធិសត្វឈ្មោះនេះ បានបំពេញ ជាកំពូលលើសលុបជាង៩បារមី ។ ប៉ុន្តែដែលពិតគឺ ព្រះពោធិសត្វបំពេញបារមីទាំង ១០ បរិបូណ៌អស់មួយជាតិ ៗ ដូចខ្ញុំនឹងលើកសេចក្ដីប្រព្រឹត្តទៅរបស់ព្រះវេស្សន្តរពោធិសត្វមកពោល (តទៅ) :

កាលព្រះវេស្សន្តរឃើញព្រះរាជបិតា ចុះរាជទណ្ឌដល់ទោស ក៏រួញព្រះទ័យមិនត្រូវការគ្រងរាជសម្បត្តិនិងវេលាដែលព្រះជនក (បិតា) ស្ដេចចេញទៅអញ្ជើញឲ្យលាព្រត (ឲ្យសឹក) ចេញមកទទួលគ្រងរាជសម្បត្តិក៏មិនទ្រង់ទទួល; អាការដូច្នេះ សឲ្យឃើញថា ដើម្បីឲ្យធ្លាក់រាជសម្បត្តិដល់អ្នកដែលត្រូវការ ទើបចាត់ជាបំពេញទានបារមី ។

កាល (ព្រះអង្គ) ទ្រង់ព្រះផ្នួសជាតាបស ចាត់ជាបំពេញសីលបារមី និងនេក្ខម្មបារមី ។

បារមីទាំងពួងដែលព្រះវេស្សន្តរបំពេញដូចពោលមកហើយ ព្រមទាំងនឹងពោលតទៅ សម្រេចបានដោយល្អ ព្រោះប្រើជា ចាត់ជាបំពេញបញ្ញាបារមី ។

តាំងពីបានទទួលពាក្យណែនាំរបស់នាងទេពធីតាឲ្យធ្វើជាខ្វិន ជាថ្លង់ ជាគ ទ្រង់តាំងព្រះហឫទ័យ (ព្រមទាំងបញ្ញាញាណ) ទទួលធ្វើតាម ព្រមដោយសេចក្ដីព្យាយាមសេចក្ដីអត់ធន់ពិត ៗ ចាត់ជាបំពេញអធិដ្ឋានបារមី វីរិយបារមី ខន្តិបារមី និងសច្ចបារមី ។

ព្រះហឫទ័យប្រកបដោយមេត្តា និងឧបេក្ខាក្នុងអ្នកដទៃ ប្រព្រឹត្តទៅគ្រប់គ្រាគ្រប់សម័យ ក្នុងវាងមុនការលុះឈាន ដូចគ្រាដែលគេតាំងសោធល្បង ក៏ទ្រង់មិនពិរោធ ទ្រង់មានអារម្មណ៍ជាកណ្ដាល ៗ ឬក្នុងគ្រាដែលលុះឈានហើយ ចាត់ជាបំពេញមេត្តាបារមី និងឧបេក្ខាបារមីដោយប្រការដូច្នេះ ។

សម្រាប់ឆ្នាំនេះ បោះពុម្ពតែមិយជាតកទី ១ (ទៀត) ដើម្បីបានថ្វាយ - ចែកដល់លោកអ្នកគួរបាន ទទួល ៗ ខ្ញុំសូមសំដែងតាមសេចក្ដីឃើញតទៅទៀតថា : សាមញ្ញជនទូទៅ បើប្រាថ្នាសេចក្ដីល្អ សេចក្ដីចំរើនដល់ខ្លួន ត្រូវចេញមុខប្រព្រឹត្តសេចក្ដីល្អ សេចក្ដីត្រូវ តាមសតិ - កម្លាំងរបស់ខ្លួន ជាការចាំបាច់ ៗ អ្នកប្រព្រឹត្តសេចក្ដីល្អសេចក្ដីត្រូវនោះ ឈ្មោះថាបំពេញបារមី ទោះបីបានខ្លះក៏ដោយ ធ្វើបានមួយដងមួយកាលក៏ដោយ ឈ្មោះថា បានបំពេញបារមីដូចគ្នា ៗ ព្រោះថា បារមីចាត់ជា ៣ ជាន់ ជាន់ទាបហៅថា បារមី ជាន់កណ្ដាលហៅថា ឧបបារមី ជាន់ខ្ពស់ហៅថា បរមត្ថបារមី ៗ ដូចយ៉ាងព្រះពោធិសត្វបានបំពេញ គឺមុន ១០ ជាតិ ទោះជាតិនោះ ៗ ជាសត្វខ្លះ ជាមនុស្សជាដើមខ្លះ ដែលលោកប្រមាណថា ៥០០ ជាតិ ការបំពេញបារមីរបស់ព្រះពោធិសត្វក្នុងជាតិប៉ុណ្ណោះ ចាត់ជាបំពេញបារមីសាមញ្ញទំនងជាធ្វើបានខ្លះ មិនបានខ្លះ ឬតាំងខ្លួនធ្វើស្បើយ ៗ ជាដើម ៗ ក្នុង ១០ ជាតិជាការបំពេញឧបបារមី ៗ ក្នុងបច្ឆិមជាតិ រហូតដល់បានត្រាស់ជាអង្គព្រះសម្មាសម្ពុទ្ធម្ចាស់ ចាត់ជាបំពេញបរមត្ថបារមី ៗ

( ចប់បារមីកថា )

មួយវយៈខាងចុងនេះ ជាព្រះរាជនិពន្ធនៃព្រះចៅវរវង្សធើ ក្រុមហ្លួងជិនវរសិរីវឌ្ឍន៍ សម្ដេចព្រះសង្ឃរាជ ប្រទេសសៀម បោះពុម្ពនៅរោងពុម្ពសោភណពិពន្ធនាការ ថ្នល់រាជបពិធ ក្រុងទេព ក្នុង ព. ស. ២៤៨១ ខ្ញុំប្រែពីភាសាសៀមមកជាភាសាខ្មែរ ។

ថ្ងៃទី ៥ ខែធ្នូ គ. ស. ១៩៦៦

**ឈឹម - ស៊ុម**

## អំពីព្រះសពសម្តេចព្រះសុធម្មាធិបតី
### ព្រះសង្ឃរាជថ្នាក់ទី ២ ព្រះបរមនាម «ភុល - ទេស» នៃគណៈធម្មយុត្តិកនិកាយ

យើងសូមរំឭកថា កិច្ចការជាកុសលដែលពុទ្ធិកសមាគម មជ្ឈមណ្ឌលកម្ពុជរដ្ឋយើងបានបំពេញ តាំងពីពេលសម្តេចជាអម្ចាស់ទ្រង់សោយព្រះទិវង្គត រហូតដល់បុណ្យថ្វាយព្រះភ្លើងគឺ ៖

១– ពុ. ម. ក. យើងបានរួបរួមជាមួយនឹងសមាគមមិត្តពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត - សមាគមមតកៈសង្គ្រោះ (សន្សំសុខ) មួយអន្លើដោយគណៈកម្មការ និងពពួកពុទ្ធបរិស័ទជើងវត្តខណ្ឌលោម, លង្កា នាក្រុងភ្នំពេញជាដើម បានប្រារព្ធធ្វើបុណ្យទក្ខិណានុប្បទានជាឧឡារិកអធិកអធ័មឧទ្ទិសកុសលថ្វាយចំពោះវិញ្ញាណក្ខន្ធនៃសម្តេចគឺ ៖

ក) នៅល្ងាចថ្ងៃទី ១៨ មិថុនា ១៩៦៦ និមន្តព្រះភិក្ខុសង្ឃចំនួន ៧៦ អង្គចំរើនព្រះបរិត្ត រួចធម្មកថិកមួយអង្គសំដែងធម្មទេសនា ដោយមានប្រគេនចតុប្បច្ច័យ និងទេយ្យវត្ថុតាមពុទ្ធានុញ្ញាត; ដល់ព្រឹកឡើងគឺថ្ងៃទី ១៩ មានកិច្ចប្រគេនភត្តពេលព្រឹក និងពេលថ្ងៃត្រង់;

ខ) នៅឱកាសពិធីបុណ្យថ្វាយព្រះភ្លើងព្រះសព ពីថ្ងៃទី ១ ដល់ទី ៥ វិច្ឆិកា ១៩៦៦ នៅទីវាលមេរុនាទីក្រុងភ្នំពេញ ពុទ្ធិកសមាគមទាំងបីគឺ ៖ ១– សមាគមគិលានុបដ្ឋានព្រះមហាក្សត្រិយាណី, ២– សមាគមមិត្តពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ៣– ពុទ្ធិកសមាគម មជ្ឈមណ្ឌលកម្ពុជរដ្ឋ បានរួបរួមគ្នារៀបចំនៅក្នុងបរិវេណវាលមេរុ នូវតូបមួយប្រកបដោយគ្រឿងសក្ការៈគ្រប់ៗគ្រាន់ ឧទ្ទិសកុសលថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធនៃសម្តេចជាអម្ចាស់ ។

យើងសូមចុះផ្សាយនូវសេចក្តីស្រង់នៃព្រះរាជជីវប្រវត្តិ និងកម្មវិធីបុណ្យថ្វាយព្រះភ្លើង ទុកជាឯកសារផង ទុកជាកិច្ចបច្ចាមរណៈផង ដើម្បីអនាគតកាលដ៏វែងឆ្ងាយតទៅ ៖

## ព្រះរាជជីវប្រវត្តិ នៃសម្តេចព្រះសុធម្មាធិបតី ព្រះសង្ឃរាជថ្នាក់ទី២
### នៃគណៈធម្មយុត្តិកនិកាយ ព្រះនាម ឥន្ទញ្ញាណោ ភុល - ទេស

សម្តេច ទ្រង់សម្ភពនៅថ្ងៃអាទិត្យ ១៥ កើត ខែស្រាពណ៍ ឆ្នាំថោះត្រីស័ក ព. ស. ២៤៣៤ (គ. ស. ១៨៩១) ក្នុងភូមិកោះរះ សង្កាត់កោះរះ ស្រុកល្វាឯម ខេត្តកណ្តាល ។ បិតា នាម ភុល មាតានាម ទៃ ។

សម្តេចកាលនៅពីកុមារ ព្រះជន្មាយុបាន ១០ ឆ្នាំ គឺក្នុងឆ្នាំជូតទោស័ក ព. ស. ២៤៤៣ (គ.- ស. ១៩០០) បិតាបាននាំយកទៅឲ្យនៅសិក្សាអក្សរសាស្ត្រក្នុងសំណាក់លោកគ្រូអាចារ្យ សុំ វត្តកោះ-

វះ គណៈមហានិកាយ ។

ព្រះជន្មាយុបាន ១១ ឆ្នាំ គឺក្នុងឆ្នាំឆ្លូវត្រីស័ក ព. ស. ២៤៤៤ (គ. ស. ១៩០១) បិតាបាននាំមកឲ្យនៅវត្តបទុមវតីរាជវរារាម ក្រុងភ្នំពេញ ក្នុងសំណាក់ព្រះគ្រូ **ម៉ៅ** ក្រុមព្រះមហាព្រហ្មមុនី **កែត** កាលនៅជាព្រះវជិរមេធា ។ សម្តេចបានសិក្សាអក្សរសាស្ត្រជាតិ លេខនព្វន្ត និងធម្មវិន័យចេះចាំស្ទាត់ល្មមប្រើការបាន ។

ព្រះជន្មាយុបាន ១៥ ឆ្នាំ បានបួសបព្វជ្ជាជាសាមណេរ ក្នុងវត្តបទុមវតីរាជវរារាម នៅថ្ងៃ ៨កើត ខែអាសាឍ ឆ្នាំម្សាញ់សប្តស័ក ព. ស. ២៤៤៨ (គ. ស. ១៩០៥) សម្តេចព្រះមង្គលទេពាចារ្យ សង្ឃនាយក ព្រះនាម **ភទ្ទគូ អៀម** កាលនៅជាសម្តេចព្រះវនរតន៍ ជាព្រះឧបជ្ឈាយ៍ ។

ព្រះជន្មាយុបាន ២១ ឆ្នាំ បានសូមឧបសម្បទាជាភិក្ខុភាវៈក្នុងពទ្ធសីមាវត្តបទុមវតីរាជវរារាម នៅថ្ងៃអាទិត្យ ១៣ កើត ខែអាសាឍ ឆ្នាំកុរត្រីស័ក ព. ស. ២៤៥៤ (គ. ស. ១៩១១) វេលាម៉ោង ៩ ព្រឹក សម្តេចព្រះមង្គលទេពាចារ្យ សង្ឃនាយក ព្រះនាម **ភទ្ទគូ អៀម** ជាព្រះឧបជ្ឈាយ៍ សម្តេចព្រះមង្គលទេពាចារ្យ សង្ឃនាយក ព្រះនាម **បញ្ញាទីបោ ព្រំ - ស៊ុក** កាលនៅជាព្រះអរិយមុនី ជាឧបសម្បទាចារ្យ បាននាមបញ្ញត្តិ (ឆាយា) ជា **ឥន្ទញាណោ** ។

## អំពីការសិក្សាព្រះបរិយត្តិធម៌

សម្តេច បានឧបសម្បទាជាភិក្ខុភាវៈរួចហើយ ប្រឹងខំសិក្សាព្រះបរិយត្តិធម៌ ព្រះត្រៃបិដក ក្នុងសំណាក់នៃលោកគ្រូអាចារ្យជាច្រើនរូប មានលោកគ្រូព្រះមហាព្រហ្មមុនី **កែត** និងព្រះបាឡាត់ព្រហ្មវិជ្ជា **ស៊្វ** ជាដើម លុះដល់មកឆ្នាំថោះសប្តស័ក ព. ស. ២៤៥៨ (គ. ស. ១៩១៥) សម្តេចបានចូលសិក្សាព្រះត្រៃបិដក ក្នុងព្រះឧបោសថរតនារាម ព្រះកែវមរកត ដែលព្រះរាជរដ្ឋាភិបាលបានបង្កើតឲ្យមានសាលាបាលីជាន់ខ្ពស់ជាដំបូង រហូតដល់ឆ្នាំវកទោស័ក ព. ស. ២៤៦៣ (គ. ស. ១៩២០) ទើបប្រឡងចេញពីសាលាបាលីជាន់ខ្ពស់ បានសញ្ញាប័ត្រជាព្រះមហាឧត្តមវិជ្ជា ក្នុងសម័យនោះ ។ សម្តេចបានបន្តការសិក្សាអក្សរសាស្ត្រថែមទៀត ដរាបដល់ចេះចាំស្ទាត់អាចអាន សរសេរ និងសន្ទនាការបាន ។

## អំពីកិច្ចការជាស្នាព្រះហស្ត

សម្តេចបានធ្វើជាលេខាធិការនៃសម្តេចព្រះមង្គលទេពាចារ្យ សង្ឃនាយក ព្រះនាម **ព្រំ - ស៊ុក**

បណ្ណាល័យជាតិ

និងជាអ្នកចាត់ចែងការខាងផ្នែកបរិយត្តិនៅសាលាបាលី - ធម្មវិន័យ ហើយធ្វើជាអាចារ្យបង្ហាត់បង្រៀនបាលី - ធម្មវិន័យ ក្នុងសាលានោះជាច្រើនឆ្នាំ ព្រមទាំងបានជួយអប់រំខាងផ្លូវសម្មាបដិបត្តិ ដល់ភិក្ខុ - សាមណេរក្នុងវត្តបទុមវតីពជវរាភមទៀតផង ។ សម្តេចទ្រង់បានធ្វើជាក្រុមជំនុំកិច្ចការផ្សេងៗ និងជាមេប្រយោគប្រឡងចេញ - ចូលសាលាបាលីជាន់ខ្ពស់ ក្នុងឋានៈជាតំណាងនៃសម្តេចព្រះសង្ឃនាយកអង្គមុនៗជាច្រើនលើក និងជាទីប្រឹក្សានៃគណៈសង្ឃ ក្នុងកិច្ចដែលទាក់ទងខាងផ្លូវពុទ្ធចក្រ និងអាណាចក្រ ហើយទ្រង់បានធ្វើជាឧបសម្បទាចារ្យបំបួសកុលបុត្តជាច្រើនរូបនៅវត្តបទុមវតីពជវរាភម និងនៅវត្តដទៃទៀតជាច្រើន ។ ជាពិសេស សម្តេចទ្រង់បានធ្វើជាឧបសម្បទាចារ្យ **ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន** កាលព្រះអង្គទ្រង់ព្រះផ្នួស ព្រមទាំងបានគង់ជួយអប់រំសម្មាបដិបត្តិ អស់មួយព្រះវស្សា ក្នុងវត្តព្រះកែវមរកត ។ មិនតែប៉ុណ្ណោះ សម្តេចទ្រង់បានជួយឧបត្ថម្ភការសិក្សាខាងព្រះពុទ្ធសាសនាគ្រប់ជាន់ថ្នាក់ និងទ្រង់បានចាត់ការឲ្យបិទមាសហោជាង - ទ្វារ - បង្អួច ព្រះវិហារវត្តបទុមវតី និងឲ្យក្រុមអភិបាលវត្ត កសាងកំពែងវត្តបទុមវតីពជវរាភម ទិសខាងត្បូង ទិសខាងកើតដែលពុំទាន់មាននៅឡើយនោះ ឲ្យកើតមានឡើង និងឲ្យបូកជញ្ជាំង - សសរព្រះវិហារវត្តបទុមវតីនាថ្នាក់ខាងក្រោមឲ្យបានស្អាតល្អ និងក្រាលឥដ្ឋពណ៌ ដាក់ភ្លើង ដាក់ផ្ចិត ចែកជាពីរបន្ទប់ បន្ទប់មួយខាងលិចឲ្យធ្វើជាសារមន្ទីរ សម្រាប់តំកល់ពិពិធភណ្ឌរបស់សង្ឃ បន្ទប់មួយខាងកើតឲ្យធ្វើជាមន្ទីរការិយាល័យនៃក្រុមអភិបាលវត្តគ្រប់ផ្នែក ដោយមានលោកអ្នកឧកញ៉ាមហាមន្ត្រី **ញឹក - នូវ** ជាអ្នកឧបត្ថម្ភក្នុងការស្ថាបនាឲ្យសម្រេចឡើង ។ និងទ្រង់បានជួយទំនុកបំរុងការកសាងព្រះវិហារ កុដិ សាលា ចេតិយ ក្នុងវត្តដទៃទៀតជាច្រើន មានវត្តគន្ធបុប្ផារាម សង្កាត់កោះរះ ស្រុកល្វាឯម ខេត្រកណ្តាលជាដើម ព្រមទាំងទ្រង់បានជួយឧបត្ថម្ភក្នុងការកុសលផ្សេងៗទៀត មានបុណ្យកឋិន និងបុណ្យសពជាដើមដោយចតុប្បច្ច័យ ត្រៃចីវរ បរិក្ខារផ្ទាល់ព្រះអង្គ ក្នុងមួយឆ្នាំៗអស់ជាច្រើន ។ ក្រៅពីនេះ សម្តេចទ្រង់បានធ្វើជាប្រធានកិត្តិយសក្នុងកិច្ចចាត់ចែងពិធីបុណ្យ ព. ស. ២៥០០ ដែលធ្វើនៅមុខស្ថានីយកាដអយស្ម័យយានក្រុងភ្នំពេញ កាលពីថ្ងៃចន្ទ ១៤ កើត ខែពិសាខ ឆ្នាំរកានព្វស័ក ព. ស. ២៥០០ (១៣ - ៥ - ៥៧) និងបាននិពន្ធរឿងករណីយកិច្ចរបស់ពុទ្ធបរិស័ទនេះ ព្រមទាំងបានតាំងគណៈកម្មការមួយក្រុមឲ្យរៀបរៀងសៀវភៅធម៌ផ្សេងៗ មានសៀវភៅវិធីថ្វាយបង្គំព្រះបាលី - ប្រែ និងកែសម្រួលវិនយវណ្ណនាចាស់ ហើយបោះពុម្ពជាថ្មីឡើងវិញ ជាដើមទៀតផង ។

ឯអគ្គការដទៃទៀត ដែលមានទាក់ទងខាងផ្លូវពុទ្ធចក្រ សម្ដេចទ្រង់បានចូលធ្វើជាសមាជិកស្ទើរតែគ្រប់អគ្គការនោះៗ ។

## អំពីព្រះគុណសម្បត្តិ

សម្ដេចជាព្រះមហាថេរមួយព្រះអង្គ ដែលទ្រង់បរិបូណ៌ដោយធម្មចរិយា សម្មាបដិបត្តិ តែងទ្រង់រក្សាទុកជានិច្ចនូវប្រពៃណីនៃសមណវង្ស គណៈធម្មយុត្តិកនិកាយ ដែលជាព្រះកេរ្ដិ៍ដំណែលមានជាប់មកអំពីសម្ដេចព្រះសុគន្ធា សង្ឃរាជាធិបតី ព្រះនាម **បញ្ញាសីលោ ប៉ាន** មិនឲ្យបាត់បង់សាបរលាបទៅឡើយ ព្រះអង្គទ្រង់មានព្រះចរិយាស្រគត់ស្រគំសមរម្យតាមសមណសារូប ទ្រង់មានព្រះហឫទ័យប្រកបដោយព្រះមេត្តាករុណា សន្ដោសប្រោសប្រណីដល់បុគ្គលទូទៅឥតរើសមុខ ទ្រង់មានព្រះបញ្ញាឈ្លាសវៃ និងទ្រង់មានព្រះហឫទ័យធ្ងន់ធ្ងរនឹងនួន ប្រកបដោយខន្តិ សោរច្ចៈ ចំពោះអនិដ្ឋារម្មណ៍ផ្សេងៗ ស្ទើរតែគ្រប់យ៉ាង ព្រះអង្គតែងទ្រង់ដឹកនាំពួកពុទ្ធបរិស័ទ ឲ្យមានការចំរើនលូតលាស់ក្នុងព្រះពុទ្ធសាសនាដោយព្រះមធ្យោបាយសន្ដិវិធី ជាហេតុឲ្យពួកពុទ្ធបរិស័ទទូទៅមានសេចក្ដីជ្រះថ្លាគោរពរាប់អានដោយភក្ដីស្មោះត្រង់ ជាការញ៉ាំងមិត្តភាព និងសាមគ្គីធម៌រវាងពួកពុទ្ធសាសនិកផងគ្នា ឲ្យមានការចំរើនលូតលាស់មាំមួនប្រសើរឡើងជាលំដាប់ រៀងដរាបមក ។

## អំពីព្រះសមណស័ក្តិ

សម្ដេចតាំងពីទ្រង់នៅក្នុងឋានៈជាភិក្ខុសាមញ្ញមក ទ្រង់ពុំដែលមានកិរិយាប្រឹងប្រែងស្វះស្វែងរកលាភ យស ដោយការលោភលោភលន់ ឬសូមដោយវាចាម្ដងណាឡើយ ។ ឯលាភយសដែលកើតឡើងដល់ព្រះអង្គ គឺអាស្រ័យបុណ្យរបស់ព្រះអង្គអំពីបុព្វេ និងព្រះធម្មចរិយា សម្មាបដិបត្តិក្នុងបច្ចុប្បន្ន ព្រមទាំងព្រះគុណសម្បត្តិសមត្ថភាព និងការដែលទ្រង់បានបំពេញព្រះភារកិច្ចជាប្រយោជន៍ក្នុងព្រះពុទ្ធសាសនាដ៏ច្រើន ទើបទ្រង់បានទទួលនូវសមណស័ក្តិជាគុណបំណាច់ ជាលំដាប់ដូចតទៅនេះ ៖

១– សម្ដេច ឧបសម្បទាជាភិក្ខុភាវៈ ក្នុងព្រះពុទ្ធសាសនាបាន ២ព្រះវស្សា ព្រះជន្មាយុបាន ២២ ឆ្នាំ ទ្រង់បានទទួលសមណស័ក្តិជាព្រះសមុហ៍ព្រហ្មសត្ថា ទីឋានា នៅថ្ងៃព្រហស្បតិ៍ ១៤រោច ខែជេស្ឋ ឆ្នាំជូតចត្វាស័ក ព. ស. ២៤៥៥ (១៣ - ៦ - ១២) ក្នុងរជ្ជកាល **ព្រះបាទសម្ដេចព្រះស៊ីសុវត្ថិចមចក្រពង្ស** និងសម័យ **សម្ដេចព្រះមង្គលទេពាចារ្យ សង្ឃនាយក** ព្រះនាម **ភទ្ទគូ អៀម** ។

២– ទ្រង់ព្រះផ្នួសបាន ១៨ ព្រះវស្សា ព្រះជន្មាយុបាន ៣៨ ឆ្នាំ ទ្រង់បានឡើងសមណស័ក្តិជាព្រះគ្រូ សុមេធមុនី ទីឋានា នៅថ្ងៃអង្គារ ១៣ កើត ខែស្រាពណ៍ ឆ្នាំរោងសំរឹទ្ធិស័ក ព.ស. ២៤៧១ (២៨-៨-២៨) ក្នុងរជ្ជកាល ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ មុនីវង្ស និងសម័យ សម្តេចព្រះមង្គលទេពាចារ្យ សង្ឃនាយក ព្រះនាម បញ្ញាទីបោ ព្រំ-ស៊ុក ។

៣– ទ្រង់ព្រះផ្នួសបាន ២៣ ព្រះវស្សា ព្រះជន្មាយុបាន ៤៤ ឆ្នាំ ទ្រង់បានឡើងសមណស័ក្តិជា ព្រះភមរា ទីពជាគណៈថ្នាក់ទី ៤ នៅថ្ងៃព្រហស្បតិ៍ ១១ រោច ខែកត្តិក ឆ្នាំចធស័ក ព.ស. ២៤៧៧ (៤-១០-៣៤) ក្នុងរជ្ជកាល ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ មុនីវង្ស និងសម័យ សម្តេចព្រះមង្គលទេពាចារ្យ សង្ឃនាយក ព្រះនាម បញ្ញាទីបោ ព្រំ-ស៊ុក ។

៤– ទ្រង់ព្រះផ្នួសបាន ២៩ ព្រះវស្សា ព្រះជន្មាយុបាន ៥០ ឆ្នាំ ទ្រង់បានឡើងសមណស័ក្តិជា ព្រះធម្មឧត្តម ទីពជាគណៈថ្នាក់ទី ២ នៅថ្ងៃអាទិត្យ ១០ រោច ខែកត្តិក ឆ្នាំរោងទោស័ក ព.ស. ២៤៨៣ (២៥-១១-៤០) ក្នុងរជ្ជកាល ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ មុនីវង្ស និងសម័យ សម្តេចព្រះមង្គលទេពាចារ្យ សង្ឃនាយក ព្រះនាម បញ្ញាទីបោ ព្រំ-ស៊ុក ។

៥– ទ្រង់ព្រះផ្នួសបាន ៣៧ ព្រះវស្សា ព្រះជន្មាយុបាន ៥៨ ឆ្នាំ ទ្រង់បានឡើងសមណស័ក្តិជា ព្រះពុធាចារ្យ ទីពជាគណៈថ្នាក់ទី ១ នៅថ្ងៃពុធ ៤ រោច ខែពិសាខ ឆ្នាំជូតសំរឹទ្ធិស័ក ព.ស. ២៤៩១ (២៦-៥-៤៨) ក្នុងរជ្ជកាល ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះចៅពជាណាចក្រកម្ពុជា និងសម័យ សម្តេចព្រះសុធម្មាធិបតី សង្ឃនាយក ព្រះនាម ពុទ្ធនាគោ អ៊ុង-ស្រី ។

៦– ទ្រង់ព្រះផ្នួសបាន ៤៤ ព្រះវស្សា ព្រះជន្មាយុបាន ៦៥ ឆ្នាំ ទ្រង់បានឡើងសមណស័ក្តិជា ព្រះសុធម្មាធិបតី សង្ឃនាយក ស្តីទី និងជាចៅអធិការវត្តបទុមវតីរាជវរារាម ក្រុងភ្នំពេញ នៅថ្ងៃអង្គារ ៣ រោច ខែមាឃ ឆ្នាំមមែសប្តស័ក ព.ស. ២៤៩៨ (៣១-១-៥៦) បន្ទាប់ពីពេលដែលសម្តេចព្រះសុធម្មាធិបតី សង្ឃនាយក ព្រះនាម ពុទ្ធនាគោ អ៊ុង-ស្រី បានទទួលអនិច្ចធម្មទៅ ក្នុងរជ្ជកាល ព្រះបាទសម្តេចព្រះនរោត្តម សុរាម្រឹត ។

៧– ទ្រង់ព្រះផ្នួសបាន ៤៥ ព្រះវស្សា ព្រះជន្មាយុបាន ៦៦ ឆ្នាំ ទ្រង់បានឡើងសមណស័ក្តិជា សម្តេចព្រះសុធម្មាធិបតី សង្ឃនាយក ពេញទី ដែលជាព្រះសង្ឃនាយកទី ៥ នៃគណៈធម្មយុត្តិកនិកាយ នៅថ្ងៃព្រហស្បតិ៍ ១៣ រោច ខែមាឃ ឆ្នាំវកអដ្ឋស័ក ព.ស. ២៤៩៦ (២៨-២-៥៧)

ក្នុងរជ្ជកាល ព្រះបាទសម្តេចព្រះនរោត្តម សុរាម្រឹត ។

៨- ទ្រង់ព្រះផ្នួសបាន ៥២ ព្រះវស្សា ព្រះជន្មាយុបាន ៧៣ ឆ្នាំ សម្តេចព្រះនរោត្តម-សីហនុ ឧបយុវរាជ ព្រះប្រមុខរដ្ឋ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ប្រគេនព្រះឋានៈជា សម្តេចព្រះសង្ឃរាជ ថ្នាក់ទី ២ នៃគណៈធម្មយុត្តិកនិកាយ ដែលជាព្រះសមណស័ក្តិខ្ពង់ខ្ពស់បំផុត ដោយទ្រង់ត្រាស់ឲ្យប្រើស័ព្ទដែលត្រូវប្រើទៅកាន់សម្តេចព្រះសង្ឃរាជ ជារាជស័ព្ទ ព្រមទាំងមានសិទ្ធិត្រូវបានបុព្វសិទ្ធិដូចខាងក្រោមនេះ ៖

- ព្រះសុវណ្ណកោដ្ឋៈពិសេស
- ផ្ចិតស្រួចពិសេស
- រងព្រះសិរពិសេស
- ទង់សម្រាប់ព្រះទីនាំងរថយន្ត

ដោយព្រះរាជក្រឹត្យលេខ ២៤ រ-វ ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ១៩៦៣ ត្រូវនឹងថ្ងៃព្រហស្បតិ៍ ១២ កើត ខែមិគសិរ ឆ្នាំថោះបញ្ចស័ក ព. ស. ២៥០៦ ។ សម្តេចទ្រង់បានបំពេញព្រះសកម្មភាព ដែលជាការកិច្ចយ៉ាងធំរបស់ព្រះអង្គ ក្នុងព្រះពុទ្ធសាសនា ដោយការគ្រប់គ្រងគណៈសង្ឃ និងដឹកនាំពួកពុទ្ធបរិស័ទ ឲ្យបានចំរើនលូតលាស់ខាងផ្លូវបរិយត្តិ និងផ្លូវបដិបត្តិ តាមព្រះមធ្យោបាយគ្រប់យ៉ាង ជាគ្រឿងទ្រទ្រង់ព្រះពុទ្ធសាសនាឲ្យបានចុំក្កើងរុងរឿងជាស្ថាពរតទៅ ។ ព្រះអង្គទ្រង់បានបំពេញព្រះការកិច្ចនេះ ដោយយកព្រះហឫទ័យទុកដាក់ពុំបានធ្វេសប្រហែសឡើយ ដរាបដល់ពេលទ្រង់សោយព្រះទិវង្គតជាអវសាន ។

## អំពីគ្រឿងឥស្សរិយយស

ដោយព្រះគុណបំណាច់ ដែលសម្តេចទ្រង់បានបំពេញព្រះការកិច្ចដែលជាប្រយោជន៍ក្នុងព្រះពុទ្ធសាសនាយ៉ាងពេញសមត្ថភាព ឲ្យបានសម្រេចលទ្ធផលល្អប្រសើរយ៉ាងនេះ ទើបព្រះអង្គទ្រង់បានទទួលអំពី សម្តេចព្រះនរោត្តម សីហនុ ឧបយុវរាជ ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភកដ៏ខ្ពង់ខ្ពស់ នូវព្រះឥស្សរិយយសដូចតទៅនេះ ៖

១- មេដាយវរសេនា អាណាចក្រកម្ពុជា ដោយប្រកាសនីយប័ត្រលេខ ២៣ ចុះថ្ងៃទី ២ ខែកុម្ភៈ គ. ស. ១៩៦២ ។

២- មេដាយមហាសិរីវឌ្ឍនមុនីសារាភរណ៍ ដោយប្រកាសនីយប័ត្រ លេខ ៣៦៩ ចុះថ្ងៃទី ១៩ ខែសីហា គ. ស. ១៩៦៤ ។

សម្តេចទ្រង់សោយព្រះទិវង្គតរំលត់ព្រះជន្មាយុ នៅវេលាម៉ោង ២១និង២០នាទី ក្នុងរាត្រីនៃថ្ងៃពុធ ៨ កើត ខែពិសាខ ឆ្នាំមមីអដ្ឋស័ក ព.ស. ២៥០៩ ត្រូវនឹងថ្ងៃទី ២៧ មេសា ១៩៦៦ ក្នុងវ័យព្រះជន្មាយុ ៧៦ ឆ្នាំ ព្រះវស្សា ៥៤ ។

បន្ទាប់អំពីពេលដែលសម្តេចទ្រង់សោយព្រះទិវង្គតក្លាមមក **សម្តេចព្រះមហាក្សត្រិយាណី ជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះនរោត្តម សីហនុ ឧបយុវរាជ** ទ្រង់ត្រាស់ព្រះរាជបញ្ជា អ្នកអង្គម្ចាស់ **នរោត្តម កន្តុល** នាយករដ្ឋមន្ត្រីយាងមកកាន់ព្រះរាជដំណាក់ នាវត្តបទុមវតីរាជវរារាម ដើម្បីទ្រង់ពិនិត្យកិច្ចការដែលត្រូវចាត់ចែងតម្កល់ព្រះបរមសពឲ្យបានស្រួលល្អ ។ នៅឱកាសនោះ មានវរជនជាច្រើនរូប ទាំងផ្នែកព្រះសង្ឃ និងគ្រហស្ថ ផ្នែកខាងព្រះសង្ឃ មាន **សម្តេចព្រះសង្ឃរាជ ថ្នាក់ទី ១** សម្តេចព្រះពោធិវង្ស **ហួត តាត** ព្រះមង្គលទេពាចារ្យ **កែវ អ៊ូច** ព្រមទាំងព្រះរាជាគណៈ ឋានា កិត្តិ-សាមណោឯទៀតជាច្រើនអង្គ ។ ផ្នែកខាងគ្រហស្ថ មានសម្តេចចៅហ្វាវាំង **ប៉ែន នុត**, អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ សិរិមតៈ**, អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ ឥស្សរោ** ប្រធានក្រុមអភិបាលវត្ត, លោក **ឆាយ ហាន់ ចេង** រដ្ឋលេខាធិការក្រសួងសាធារណសុខាភិបាល, ឯកឧត្តម **អ៊ិន តាំ** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងធម្មការ, លោកអ្នកឧកញ៉ា **ទ្រិញ វ៉ាញ** អនុរដ្ឋលេខាធិការក្រសួងធម្មការ, លោក **ថៅ ប៉េងថុង** អគ្គនាយកក្រសួងសាធារណសុខាភិបាល, លោកអ្នកឧកញ៉ាមហាមន្ត្រី **ញិក នូវ**, ឯកឧត្តម **ម្សៀប គន្ធ**, លោក **កែ មាស** និងឥស្សរជនឯទៀតជាច្រើនរូប ព្រមទាំងពួកពុទ្ធបរិស័ទទាំងឡាយ ដែលយើងសូមអភ័យទោសដោយពុំបានរៀបរាប់ឲ្យបានសព្វគ្រប់ក្នុងទីនេះ បានស្តេចយាង-និមន្ត-អញ្ជើញមកជួបជុំកុះករ សំដែងនូវមរណទុក្ខ និងសេចក្តីស្តាយស្រណោះអាឡោះអាល័យដោយសមានចិត្តចំពោះព្រះបរមសព ជាយ៉ាងក្រៃពេក លុះដល់ម៉ោង ២៤ ក៏បាននាំគ្នាដង្ហែព្រះបរមសពចេញពីព្រះដំណាក់ ទៅតម្កល់លើមញ្ចាសនៈក្នុងមហាឧបដ្ឋានសាលា ដែលមានតាក់តែងលំអទៅដោយប្រទីបផ្កាលា ភ្ញីផ្កាយ៉ាងប្រណីត និងគ្រឿងសក្ការបូជាដ៏រុងរឿងគួរជាទីទស្សនា ។

## អំពីការថ្វាយព្រះសុគន្ធវារី

លុះព្រឹកឡើងថ្ងៃទី ២៨ ខែមេសា ១៩៦៦ វេលាម៉ោង ១៦ នៅក្នុងវត្តបទុមវតីរាជវរារាម មានការជួបជុំព្រះសង្ឃ ព្រះរាជវង្សានុវង្ស ប្រធានសភាទាំងពីរ គណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការ និងពួកពុទ្ធបរិស័ទជាច្រើន ។

ផ្នែកខាងព្រះសង្ឃ មាន សម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជថ្នាក់ទី១ សម្ដេចព្រះពោធិវង្ស ហួត តាត ព្រះពុទ្ធាចារ្យ ទេព លឿង ព្រះមង្គលទេពាចារ្យ កែវ អ៊ូច និងព្រះរាជាគណៈឯទៀតទាំងពីរគណៈជាច្រើនអង្គ ។

ផ្នែកខាងគ្រហស្ថមាន សម្ដេចក្រុមព្រះ ស៊ីសុវត្ថិ មុនីរ៉េត, សម្ដេចព្រះរាជកន្និដ្ឋារស្មីសោភ័ណ ព្រមទាំងព្រះរាជវង្សានុវង្ស, សម្ដេចចៅហ្វាវាំង ប៉ែន នុត ក្រុមឧត្តមប្រឹក្សានៃព្រះរាជបល្ល័ង្ក, ប្រធានសភាទាំងពីរ គណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការ និងពួកពុទ្ធបរិស័ទជាច្រើនទៀត បានស្ដេចយាង-និមន្តអញ្ជើញមករង់ចាំធ្វើគារវកិច្ចដោយស្វាមីភក្តិចំពោះ សម្ដេចព្រះមហាក្សត្រិយាណី ជាអម្ចាស់ជីវិតលើត្បូង និងសម្ដេចព្រះនរោត្តម សីហនុ ឧបយុវរាជ ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភកដ៏ខ្ពង់ខ្ពស់ ។

លុះដល់ម៉ោង ១៧ ព្រះមហាក្សត្រទាំងពីរព្រះអង្គ ដោយមានព្រះរាជបរិពារផ្ទាល់ព្រះអង្គតាមហែផង ស្ដេចយាងដល់, ទាហានក្រុមរក្សាព្រះអង្គ និងក្រុមក្មេងព្រះរាជទ្រព្យ ធ្វើគារវកិច្ចថ្វាយជាព្រះកិត្តិយស, កាលព្រះអង្គទ្រង់បានទទួលនូវគារវកិច្ចហើយ ក៏ស្ដេចយាងចូលទៅកាន់មហាឧបដ្ឋានសាលា ថ្វាយបង្គំព្រះរតនត្រ័យ និងព្រះបរមសពរួចហើយ ព្រះអង្គក៏ទ្រង់ប្រារព្ធព្រះរាជពិធីថ្វាយព្រះសុគន្ធវារី ចំពោះព្រះបរមសពតាមប្រពៃណី ដោយមានលោកអ្នកឧកញ៉ាមហាមន្ត្រី ទី គិមសួ នាំយកព្រះសុគន្ធវារីទៅថ្វាយព្រះមហាក្សត្រ ព្រះអង្គទ្រង់យកព្រះសុគន្ធវារីនោះ ទៅស្រោះព្រំព្រះបរមសពជាការសូមខមាទោស និងការថ្វាយព្រះរាជកុសល ដើម្បីព្រះបរមសុខចំពោះព្រះវិញ្ញាណក្ខន្ធនៃសម្ដេច ។ ពេលនោះ បារគូបានថ្វាយស័ង្ខ ក្រុមក្មេងព្រះរាជទ្រព្យក៏បន្លឺបទមរណសញ្ញា គួរឲ្យមានសេចក្ដីព្រឺព្រួចរំជួលញាប់ញ័រក្នុងចិត្ត និងសង្វេគពន់ពេកណាស់ ។ បន្ទាប់អំពីព្រះមហាក្សត្រមក ទើប សម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជថ្នាក់ទី១ សម្ដេចព្រះពោធិវង្ស ហួត តាត សម្ដេចព្រះសុធម្មាធិបតី សង្ឃនាយក ទេព លឿង និងក្រុមឧត្តមប្រឹក្សាព្រះរាជបល្ល័ង្ក ព្រះរាជវង្សានុវង្ស ប្រធានសភាទាំងពីរ គណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការ ព្រះសង្ឃរាជាគណៈ សិស្សានុសិស្ស ជាលំដាប់មកដរាបដល់អស់ចំនួន ។

លុះចប់ព្រះរាជពិធីថ្វាយព្រះសុគន្ធវារីសព្វគ្រប់ហើយ សម្ដេចព្រះនរោត្តម សីហនុ ឧបយុវរាជ ព្រះប្រមុខរដ្ឋ ទ្រង់បានប្រកាសតែងតាំងព្រះពុទ្ធាចារ្យ ទេព លឿង ជា សម្ដេចព្រះសុធម្មាធិបតី សង្ឃនាយក នៃគណៈធម្មយុត្តិកនិកាយ ដើម្បីគ្រប់គ្រងគណៈសង្ឃតទៅ ទ្រង់តាំងព្រះមង្គលទេពា-

ចារ្យ **កែវ អ៊ួច** ជាសម្តេចព្រះមង្គលទេពាចារ្យ ឧត្តមប្រឹក្សា រួចហើយ ព្រះមហាក្សត្រទ្រង់ស្តេចព្រះរាជនិវត្តទៅកាន់ព្រះបរមរាជវាំងវិញ ដោយមានព្រះរាជបរិពារផ្ទាល់ព្រះអង្គតាមហែ និងមានក្រុមទាហានធ្វើការកិច្ច ដូចកាលស្តេចយាងមក ។

## អំពីពិធីបុណ្យទក្ខិណានុប្បទាន

ចាប់តាំងពីថ្ងៃទី ២៨ ខែមេសា ១៩៦៦ មក ក្រោយពេលដែលបានធ្វើពិធីថ្វាយព្រះសុគន្ធរាវរួចសព្វគ្រប់ ពួកស្នំ ដោយមានវរជនមានលោកអ្នកឧកញ៉ាមហាមន្ត្រី **ញ៉ិក នូវ** និងឯកឧត្តម **អ៊ិន តាំ** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងធម្មការ ជាដើមជួយចាត់ចែងផង ក៏បានរៀបចំព្រះបរមសពថ្វាយគង់ក្នុងព្រះកោដ្ឋ ហើយតំកល់លើបញ្ចាសនៈដ៏ប្រសើរ ដើម្បីរង់ចាំការធ្វើព្រះមេរុថ្វាយព្រះភ្លើងហើយ ។ នៅឱកាសនេះ ពួកពុទ្ធបរិស័ទគ្រប់ប្រភេទ និងគណៈកម្មការចាត់ការបុណ្យ ក្រោមព្រះរាជូបត្ថម្ភដ៏ខ្ពង់ខ្ពស់នៃ **សម្តេចព្រះមហាក្សត្រិយាណី ជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះនរោត្តម សីហនុ ឧបយុវរាជ** ដែលមានអ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ ឥស្សរោ** ជាប្រធានក្រុមអភិបាលវត្ត និងអ្នកអង្គម្ចាស់ក្សត្រី **នរោត្តម វឌ្ឍននារី** ជាព្រះជាយា និងព្រះរាជវង្សានុវង្សជាដើម ព្រមទាំងអស់លោកវរជននានា អង្គការសមាគមនានា សិស្សានុសិស្សទាំងឡាយ ដែលមានសទ្ធាជ្រះថ្លា បានប្រារព្ធធ្វើបុណ្យទក្ខិណានុប្បទាន ដោយមាននិមន្តព្រះសង្ឃចំរើនព្រះបរិត្ត - ទេសនា - សត្តប្បករណ៍ - វេរភត្តឧទ្ទិសជាព្រះរាជកុសលថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធសម្តេចជារៀងរាល់ថ្ងៃ ឥតមានអាក់ខានថ្ងៃណាមួយឡើយ ដោយការធ្វើជាចំមុខតែម្នាក់ឯងក៏មាន ដោយរួបរួមជាមួយក្រុមញាតិមិត្តធ្វើក៏មាន ទៅតាមធនធាន និងសទ្ធារបស់ខ្លួនៗ និងមានបារគូថ្វាយស័ង្ខ ភ្លេងខ្លងផ្អាក់ប្រគំថ្វាយជារាល់ថ្ងៃផង គឺនៅម៉ោង៦ម្តង ម៉ោង១១ម្តង ម៉ោង១៨ម្តង ម៉ោង២៤ម្តង រហូតដល់ថ្ងៃថ្វាយព្រះភ្លើងជាបរិយោសានៗ

## អំពីពិធីបុណ្យថ្វាយព្រះភ្លើង

ក្រោយពេលដែលបានតំកល់ព្រះបរមសព ធ្វើបុណ្យទក្ខិណានុប្បទានថ្វាយព្រះរាជកុសលអស់រយៈពេលចំនួនជាង ៦ ខែមក ព្រះរាជរដ្ឋាភិបាល ក្រោមព្រះរាជាធិបតីភាពនៃ **សម្តេចព្រះមហាក្សត្រិយាណី ជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះនរោត្តម សីហនុ ឧបយុវរាជ** បានចាត់ការស្ថាបនាព្រះមេរុនៅវាលព្រះមេរុ មានទំហំទទឹង បណ្តោយ និងកំពស់ សមតាមព្រះកិត្តិយសនៃសម្តេចព្រះសង្ឃរាជ ដ៏ប្រកបទៅដោយក្បាច់រចនាសមរម្យល្អ ប្រដាប់ដោយបញ្ចាសម្រាប់តំកល់

ព្រះកោដ្ឋក្នុងព្រះមេរុ ៧ ជាន់ មានសមសាន ៤ ជាប់នឹងរាជវ័តិព័ទ្ធជុំវិញព្រះមេរុ មានគ្រឿងតាំងគ្រឿងសក្ការបូជា ៨ ក្នុងវែវខាងជើងព្រះមេរុស្រេចហើយ ក៏កំណត់កម្មវិធីបុណ្យថ្វាយព្រះភ្លើងព្រះបរមសព អស់រយៈពេលចំនួន ៤ យប់ ៥ ថ្ងៃ ៖

## ថ្ងៃទី ១ គឺថ្ងៃអង្គារ ៤ រោច ខែកត្តិក ឆ្នាំមមីអដ្ឋស័ក ព. ស. ២៥០៩ (១ - ១១ - ១៩៦៦)

**ម៉ោង ១៤,០០** : – ប្រជុំព្រះសង្ឃរាជាគណៈ - ឋានានុក្រម - ឧបាសក - ឧបាសិកា ព្រមទាំងមន្ត្រីភ្នាក់ងាររាជការ នៅវត្តបទុមវតីរាជវរារាម

– រៀបក្បួនដង្ហែព្រះសពតំកល់លើព្រះរាជរថ

– និមន្តព្រះសង្ឃវត្តបទុមវតី ៧៦ អង្គ ថ្វាយសត្តប្បករណាភិធម្ម "តាមព្រះជន្មសម្តេច" ។

**ម៉ោង ១៥,០០** : – រំកិលព្រះសព ចំពោះព្រះភក្ត្រសម្តេចព្រះមហាក្សត្រិយាណី ជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះប្រមុខរដ្ឋ ។

**ម៉ោង ១៥,៣០** : – ក្បួនហែចេញពីវត្តបទុមវតីរាជវរារាម ទៅតាមវិថីបទុមវតី វិថីឧកញ៉ាឈុនសំរាក ១០ នាទី នៅត្រង់ជ្រុងវិថីឧកញ៉ាឈុន និងមហាវិថីព្រះនរោត្តម និមន្តព្រះសង្ឃវត្តលង្កា ៧៦ អង្គ ថ្វាយសត្តប្បករណាភិធម្ម ក្បួនដង្ហែបន្តដំណើរទៅតាមមហាវិថីព្រះនរោត្តម - មហាវិថីកុសមៈ - តវិថីព្រះបាទស៊ីសុវត្ថិ - មហាវិថីសុធារស បត់ចូលព្រះមេរុ

– និមន្តសម្តេចព្រះពោធិវង្ស ហួត - តាត ព្រះអភិធម្ម ។

**ម៉ោង ១៦,៣០** : – ជួបជុំព្រះរាជវង្សានុវង្ស - គណៈរដ្ឋមន្ត្រី - អនុរដ្ឋលេខាធិការ - អ្នកតំណាងរាស្ត្រទីប្រឹក្សាព្រះរាជាណាចក្រ - នាម៉ឺនសព្វមុខមន្ត្រី "ទាហាន - ស៊ីវិល" ស្តេចយាង - អញ្ជើញមករង់ចាំទទួលព្រះសពនៅទីព្រះពន្លាខាងត្បូង

– លុះក្បួនហែមកដល់ព្រះមេរុហើយ សម្តេចព្រះសង្ឃនាយក ព្រមទាំងរាជាគណៈខ្ទះ ខាងគណៈធម្មយុត្តរង់ចាំទទួលព្រះសព

– លើកព្រះកោដ្ឋតំកល់លើរាជទេន្ទូរ ហែប្រទក្សិណព្រះមេរុ ៣ ជុំ រួចស្តេចយាងទៅតំកល់លើបញ្ចារ ៧ ជាន់ ។

ម៉ោង ១៧,៣០ : – សម្តេចព្រះមហាក្សត្រិយាណី ជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះប្រមុខរដ្ឋ ស្តេចយាងជាព្រះរាជាធិបតី ។ ក្រុមឧត្តមប្រឹក្សាព្រះរាជបល្ល័ង្ក និងព្រះរាជបរិ-ពារផ្ទាល់តាមហែ ។ ទាហានក្រុមរក្សាព្រះអង្គ ក្រុមខេមរកុមារិទាំង ៣ក្រុម ក្រុមក្មេងកងវរសេនាតូចរក្សាព្រះអង្គ ក្រុមតន្ត្រីព្រះរាជទ្រព្យ ថ្វាយគារវកិច្ចតាមទម្លាប់

– និមន្តព្រះរាជាគណៈ - ឋានានុក្រម គណៈមហានិកាយ ៧៦អង្គ ថ្វាយសក្ក-ប្បករណាភិធម្ម ។

ម៉ោង ១៨,០០ : – អុជប្រទីបផ្កាលានៅលើតុ និងព្រះមេរុ ជាសក្ការបូជា ។

ម៉ោង ២០,០០ : – និមន្តព្រះសង្ឃ ១៦អង្គចំរើនព្រះបរិត្ត - សូត្រព្រះធម៌តាមទិសមសានក្នុងព្រះមេរុ

ម៉ោង ២០,៣០ : – អុជកាំជ្រួចភ្ញីទៀន ។

ម៉ោង ២១,៣០ : – និមន្តព្រះធម្មកថិក ១ អង្គទេសនា - សត្វី ៤ អង្គ ។

## ថ្ងៃទី ២ គឺថ្ងៃពុធ ៥ រោច ខែកត្តិក ឆ្នាំមមីអដ្ឋស័ក ព. ស. ២៥០៩ (២ - ១១ - ៦៦)

ម៉ោង ១០,០០ : – ប្រគេនភត្តាហារព្រះសង្ឃ១៦អង្គ ដែលចំរើនព្រះបរិត្តពីល្ងាចនិងសូត្រព្រះធម៌។

ម៉ោង១៨ដល់២២ : – របៀបពិធីបុណ្យដូចថ្ងៃទី ១ ។

ម៉ោង ២៣,០០ : – ក្រុមភ្នាក់ងារ រៀបចំរំកិលព្រះកោដ្ឋចុះតាកទីបញ្ចា ទៅតំកល់នៅថែវខាងលិច រៀបគ្រឿងជាន់សម្រាប់ថ្វាយព្រះភ្លើងព្រះសព រួចហើយសូមស្តេចយាងតែ ឡតព្រះកោដ្ឋ តំកល់លើគ្រឿងជាន់ក្នុងព្រះមេរុវិញ ។

## ថ្ងៃទី ៣ គឺថ្ងៃព្រហស្បតិ៍ ៦ រោច ខែកត្តិក ឆ្នាំមមីអដ្ឋស័ក ព. ស. ២៥០៩ (៣-១១-៦៦)

ម៉ោង ១០,០០ : – របៀបបុណ្យដូចថ្ងៃទី ២ ។

ម៉ោង ១៦,៣០ : – ជួបជុំព្រះរាជវង្សានុវង្ស - គណៈរដ្ឋមន្ត្រី - អនុរដ្ឋលេខាធិការ - អ្នកតំណាងរាស្ត្រ ទីប្រឹក្សាព្រះរាជអាណាចក្រ - អង្គទូតនានា - នាម៉ឺនសព្វមុខមន្ត្រី ខ្មែរ - បរទេស "ទាហាន - ស៊ីវិល" មន្ត្រីសង្ឃទាំងពីរគណៈ - រាជាគណៈ - ឋានានុក្រម - ឧបាសក - ឧបាសិកា ស្តេចយាង - និមន្ត - អញ្ជើញមកដល់ ។

ម៉ោង ១៧,០០ : – សម្តេចព្រះមហាក្សត្រិយាណី ជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះប្រមុខរដ្ឋ

ស្ដេចយាងជាព្រះរាជាធិបតី ។ ក្រុមឧត្ដមប្រឹក្សានៃព្រះរាជបល្ល័ង្ក និងព្រះរាជបរិពារផ្ទាល់តាមហែ ។ ទាហានក្រុមរក្សាព្រះអង្គ ក្រុមខេមរកុមារនិទ្ទទាំង៣ក្រុម ក្រុមក្មេងកងវរសេនាតូចរក្សាព្រះអង្គ ក្រុមតន្ត្រីព្រះរាជទ្រព្យ ថ្វាយគារវកិច្ចតាមទម្លាប់

– រដ្ឋមន្ត្រីក្រសួងធម្មការ ថ្វាយសុន្ទរកថា

– និមន្តព្រះសង្ឃទាំងពីរគណៈ ចំនួន ៧៦ អង្គ ថ្វាយសត្តប្បករណាភិធម្ម

– ថ្វាយផ្កាខ្ញុំម៉ង់ទ្ងន់

– សម្ដេចព្រះប្រមុខរដ្ឋ ទ្រង់ថ្វាយព្រះភ្លើង ។

ម៉ោង ១៩,៣០ : – និមន្តសម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជថ្នាក់ទី ១ ទេសបន្ទុំ ។

ម៉ោង ២០,០០ : – និមន្តព្រះធម្មកថិក ១ អង្គ ទេសនាមុខភ្លើង ។

ម៉ោង២១ដល់២៤: – របៀបបុណ្យដូចថ្ងៃទី ២ តែគ្មានការសូត្រព្រះធម៌ទេ ។

ថ្ងៃទី៤ គឺថ្ងៃសុក្រ៧ រោច ខែកត្តិក ឆ្នាំមមីអដ្ឋស័ក ព. ស. ២៥០៩ (៤-១១-៦៦)

ម៉ោង ៧,០០ : – និមន្តព្រះសង្ឃ ៤ អង្គធាកប្រែព្រះរូប និងថ្វាយពិធីព្រាហ្មណ៍

– និមន្តព្រះសង្ឃ ៣ អង្គ ទទួលគ្រឿងសាមហាប ។

ម៉ោង ៨,០០ : – សម្ដេចព្រះមហាក្សត្រិយាណី ជាអម្ចាស់ជីវិតលើត្បូង និងសម្ដេចព្រះប្រមុខរដ្ឋ ស្ដេចយាងជាព្រះរាជាធិបតី ។ ក្រុមឧត្ដមប្រឹក្សានៃព្រះរាជបល្ល័ង្ក និងព្រះរាជបរិពារផ្ទាល់តាមហែ ។ ទាហានក្រុមរក្សាព្រះអង្គ ក្រុមខេមរកុមារនិទ្ទទាំង៣ក្រុម ក្រុមក្មេងកងវរសេនាតូចរក្សាព្រះអង្គ ក្រុមតន្ត្រីព្រះរាជទ្រព្យ ថ្វាយគារវកិច្ចតាមទម្លាប់

– ហែព្រះអដ្ឋិទៅតំកល់ក្នុងព្រះពន្លាសិន

– ឯព្រះអង្គារដង្ហែទៅបំផុងនៅទន្លេចតុមុខ

– ក្មាក់ងារព្រះបរមរាជវាំង រៀបចំគ្រឿងបញ្ចាឡើងវិញ ។

ម៉ោង ១០,០០ : – រៀបចំវេរភត្តប្រគេនព្រះសង្ឃ ១៦ អង្គ ។

ម៉ោង ១៧,០០ : – សម្ដេចព្រះមហាក្សត្រិយាណី ជាអម្ចាស់ជីវិតលើត្បូង និងសម្ដេចព្រះប្រមុខរដ្ឋ

ស្ដេចយាងជាព្រះរាជាធិបតី ។ ក្រុមឧត្ដមប្រឹក្សានៃព្រះរាជបល្ល័ង្ក និងព្រះរាជ-
បរិពារផ្ទាល់តាមហែ ។ ទាហានក្រុមរក្សាព្រះអង្គ ក្រុមខេមរកូមិន្ទ ទាំង៣ក្រុម
ក្រុមក្មេងកងវរសេនាតូចរក្សាព្រះអង្គ ក្រុមតន្ត្រីព្រះរាជទ្រព្យ ថ្វាយគារវកិច្ច
តាមទម្លាប់

– ស្ដេចយាងព្រះអង្គគង់ក្នុងព្រះកោដ្ឋមាស ហើយដង្ហែទៅតំកល់លើបញ្ជរវិញ

– ថ្វាយសក្ការបូជាករណាកិច្ច ។

ម៉ោង ២០,០០ : – និមន្តព្រះសង្ឃ ២០ អង្គចំរើនព្រះបរិត្ត រួចហើយនិមន្តធម្មកថិក ១ អង្គ សំដែង
ព្រះធម៌ទេសនាបឋមត្រាស់ ។ សត្តី ៤ អង្គ ។ លុះចប់ព្រះធម៌ទេសនា
ហើយ រៀបចំអភិសេកព្រះពុទ្ធរូបមាស និមន្តព្រះសង្ឃ ២ អង្គសូត្រពុទ្ធាភិ-
សេកដរាបដល់ភ្លឺ ។

## អំពីការបញ្ចុះព្រះអដ្ឋិក្នុងព្រះចេតិយធំ

### ថ្ងៃទី៥ គឺថ្ងៃសៅរ៍ ៨ រោច ខែកត្តិក ឆ្នាំមមីអដ្ឋស័ក ព. ស. ២៥០៩ (៥-១១-៦៦)

ម៉ោង ៧,០០ : – ជួបជុំព្រះសង្ឃរាជាគណៈ – ឋានានុក្រម – ឧបាសក ឧបាសិកា ស្ដេចយាងព្រះ
អដ្ឋិតំកល់លើព្រះសលៀងហែទៅវត្តបទុមវតីរាជវរារាម ។

ម៉ោង ៨,០០ : – ជួបជុំព្រះរាជវង្សានុវង្ស – គណៈរដ្ឋមន្ត្រី – អនុរដ្ឋលេខាធិការ – អ្នកតំណាងរាស្ត្រ
ទីប្រឹក្សាព្រះរាជអាណាចក្រ – នាម៉ឺនសព្វមុខមន្ត្រី – ឧបាសក ឧបាសិកា ស្ដេច
យាង – អញ្ជើញជួបជុំនៅទីព្រះពន្លាមុខព្រះចេតិយធំវត្តបទុមវតី ។

ម៉ោង ៨,៣០ : – សម្ដេចព្រះមហាក្សត្រិយាណី ជាអម្ចាស់ជីវិតលើត្បូង និងសម្ដេចព្រះប្រមុខរដ្ឋ
ស្ដេចយាងជាព្រះរាជាធិបតី ។ ក្រុមឧត្ដមប្រឹក្សានៃព្រះរាជបល្ល័ង្ក និងព្រះរាជ-
បរិពារផ្ទាល់តាមហែ ។ ទាហានក្រុមរក្សាព្រះអង្គ ក្រុមខេមរកូមិន្ទ ទាំង៣ក្រុម
ក្រុមក្មេងកងវរសេនាតូចរក្សាព្រះអង្គ ក្រុមតន្ត្រីព្រះរាជទ្រព្យ ថ្វាយគារវកិច្ច
តាមទម្លាប់

– និមន្តព្រះសង្ឃរាជាគណៈ ៨ អង្គឆាក

– រដ្ឋមន្ត្រីក្រសួងធម្មការ លើកព្រះអដ្ឋិថ្វាយសម្ដេចព្រះប្រមុខរដ្ឋ សម្ដេចព្រះ

ប្រមុខរដ្ឋ ទ្រង់ទទួលយកទៅបញ្ចុះតំកល់ក្នុងព្រះចេតិយធំ

– ព្រះសង្ឃសូត្រជយន្តោ

– ភ្លេងពិណពាទ្យ

– និមន្តព្រះសង្ឃ ៧៦ អង្គ ថ្វាយសត្តប្បករណាភិធម្ម ។

**ម៉ោង ១០,០០** : – វេរភត្តប្រគេនព្រះសង្ឃដូចថ្ងៃទី ៤ ។

**ម៉ោង ១៤,០០** : – និមន្តធម្មកថិក ៣ អង្គ ទេសនាសង្គាយនា និមន្តលោកអានត្រ័យ ៤ អង្គ លោកហត្ថបាស ២០ អង្គ នៅព្រះវិហារវត្តបទុមវតីរាជវរារាម ។

## ពិធីបុណ្យព្រះបរមសពអស់តែប៉ុណ្ណោះ

### ព្រះរាជជីវប្រវត្តិសង្ខេប

និពន្ធដោយ

**ព្រះបទុមវង្សា ភោគ – ផន ហៅ ចេង**

ចប់

### ពុទ្ធភាសិត

ពុំមានភ្លើងណាស្មើដោយភ្លើងគឺរាគៈឡើយ, ពុំមានទោសណាស្មើដោយទោសគឺទោសៈឡើយ, ពុំមានទុក្ខទាំងឡាយណាស្មើដោយទុក្ខគឺខន្ធ ៥ ឡើយ, ពុំមានសុខណាក្រៃលែងជាងសន្តិសុខគឺព្រះនិព្វានឡើយ ។

*ធម្មបទដ្ឋកថា សុខវគ្គ*

# BOUDDHA SASANA
## ESSAI DE COMPREHENSION
### par S.A.R. SAMDECH KROM PREAH SISOWATH MONIRETH

Nous constations en nous, autour de nous, parmi nos parents et connaissances, que l'existence que nous vivons, est faite de moments de joies et de douleurs qui se vivent et se mélangent, à croire qu'ils provoquent inévitablement la naissance de l'un, de l'autre en une chaîne sans fin. Nous souhaitons que notre vie soit remplie de bonheur, le plus de bonheur possible et nous désirons éloigner d'elle les peines, les chagrins, les souffrances qui pourront l'assombrir. Dans ce but, nous faisons, jour et nuit, tout ce qui est en notre pouvoir. Mais, quels que soient les efforts que nous déployons, les vœux que nous formulons, les prières qu'il nous arrive à murmurer ou à penser, l'obstination dont nous sommes capables, il faut bien avouer que jamais nous n'avons réussi, jamais nous ne réussissons et jamais nous réussirons pleinement dans cette entreprise.

Certains, las de la poursuite qui leur semble ne pouvoir finir, se disent : « C'est la vie » et l'acceptent comme telle. Ils la prennent comme elle leur vient. Quand ils souffrent, ils se lamentent. Quand la souffrance disparaît, ils recueillent le plaisir qui surgit et s'en réjouissent. D'autres plus comblés de fortunes et de santé s'estiment heureux et oublient facilement, tels les enfants, les instants pénibles et désagréables par où ils ont passé. Ils estiment que leur vie mérite d'être vécue. D'autres encore et enfin, plus accablés par l'infortune et les misères de toutes sortes courbent la tête ou se révoltent contre leur sort, contre l'adversité dont ils sont les victimes. Il en est qui mettent fin à leur jour, par désespoir insurmontable ou par dégoût d'une vie qu'ils comparent à un enfer.

Quoiqu'ils fassent, les uns et les autres, quels que puissent être les progrès de la science moderne qui apportent des améliorations certaines aux conditions matérielles des êtres humains, ils ne changent rien aux constances de la vie qui sont naissance, vieillesse, mort, qu'accompagnent la joie et la douleur avec leur cortège de la mentation, d'insatisfaction, d'incertitude.

En face de cette existence terrestre qui paraît inéluctable, c'est une question de choix de chacun de nous et cette question se pose depuis que le monde existe.

La réponse est donc dans la recherche du Salut. Dès lors, naissent des religions, des philosophies dont les fondateurs proposent aux communs des mortels la voie à suivre. Les uns la trouvent dans un Dieu dont tout émane, qui règle tout, qui juge de tout et duquel l'humaine créature dépend étroitement. On doit s'incliner devant sa volonté, on doit s'y soumettre. Le moindre bonheur est un don à votre mérite ; le moindre malheur est une punition pour votre démérite. Pour avoir le premier et pour éviter la seconde, il faut lui adresser des prières soit par vous-même soit par l'intermédiaire des prêtes. Mais ces prières peuvent ne pas être entendues de ce Dieu et rien ne changera. Et votre vie continuera dans une croyance dont l'échec ne saurait être expliqué que par votre propre faute. Priez encore. Priez toujours. L'espoir fait vivre.

Les autres proposent la purification du corps et de l'esprit pour laquelle ils se livrent à des macérations poussées à l'extrême limite des possibilités humaines. Ils s'imaginent, ce faisant, avoir trouvé la Voie sinon le Salut. C'est leur croyance dans laquelle ils savourent leur satisfaction.

Ces réponses laissent, cependant, le problème entièrement posé, parce qu'elles sont insuffisantes, puisqu'elles ne montrent pas les véritables causes de cette « maladie » qu'est la vie, ni les remèdes qui sont sensés la guérir. Elles la font dépendre d'une ou des créations de l'esprit, alors qu'elles taisent la réalité, ne se contentant des solutions toutes faites, des satisfactions de commande et d'inutiles tortures corporelles.

Il y eut un homme qui a su saisir cette réalité. Ce fut le Bouddha Sakyamuni. Il y a de cela plus de 2.500 ans et depuis lors, son enseignement ne varie pas malgré les écoles et les sectes qui se sont multipliées et qui, bien que paraissant divergentes, continuent à se réclamer de lui.

Après l'Illumination, le Bouddha Sakyamuni, assis au pied d'un banian, s'interrogea en ces termes : — « J'ai découvert cette vérité profonde, difficile à apercevoir, difficile à comprendre, remplissant le cœur de paix, sublime, surpassant toute pensée, abstruse, que seul le sage peut saisir. Dans le tourbillon du monde, s'agite l'humanité adonnée à la convoitise, toute tendue vers la convoitise, trouvant dans le monde son plaisir. Pour l'humanité qui s'agite dans le tourbillon du monde, ce sera une chose difficile à saisir que la loi de causalité, l'enchainement des causes et des effets ; et ce sera, aussi, une chose tout à fait difficile à saisir que l'extinction de toutes les formations — ( Samkhara )—, l'extinction de la convoitise, l'absence de passion, la paix du cœur, Nibbana ! Si je prêche cette doctrine et que les hommes ne soient point capables de me comprendre, il n'en résultera que de la fatigue et de la tristesse pour moi ».

— « Pourquoi annoncerai-je ce que j'ai conquis au prix de tant d'efforts ? Cette doctrine sera incompréhensible à tous ceux que dominent le désir et la haine. Adonnés à la convoitise, environnés de ténèbres, ils ne pourront atteindre cette vérité contraire à leurs tendances, difficile à atteindre, profonde, inaccessible à l'esprit grossier ».

Puis, il réfléchit et regarda le monde avec « l'œil d'un bouddha », c'est-à-dire avec une vision parfaite à laquelle rien n'échappe. Il se dit :

— « Comme dans un étang de lotus, parmi les roses des eaux, lotus bleus, lotus blancs nés dans l'eau, montant dans l'eau, les uns n'émergent pas de l'eau et fleurissent au fond. D'autres s'élèvent jusqu'à la surface de l'eau et d'autres émergent de l'eau et l'eau ne mouille plus leur fleur. De même, il y a des êtres dont l'œil « spirituel » est recouvert d'une épaisse poussière, des êtres d'un esprit vif et des êtres d'un esprit obtus, des êtres d'un caractère noble et des êtres d'un caractère bas, des êtres aisés à instruire et des êtres difficiles à instruire, beaucoup qui vivent dans la crainte à la pensée de l'autre monde et de leurs fautes ».

L'ayant vu ainsi, il se décida :

« Large soit ouverte la porte de l'Eternel ! Que celui qui a des oreilles entende ! :

— « Je songeais à ma lourde tâche, c'est pourquoi je n'ai pas encore annoncé aux hommes la Loi douce et salutaire ».

Cette Doctrine, cette loi que le Bouddha a découverte, il l'a formulée comme suit :

— « Prêtez l'oreille, l'éternel est trouvé. Si vous suivez la voie que je vous indique, en peu de temps, vous atteindrez le plus haut but de la sainteté; pour lequel les jeunes gens de nobles familles abandonnent leur demeure et embrassent la vie religieuse; en cette vie vous possèderez la vérité, la connaissance et la voyant vous-mêmes face à face ».

— « Il existe deux extrêmes que celui qui vit religieusement doit s'écarter. L'un est une vie toute abandonnée à la sensualité et à la jouissance; cela est vil, grossier et vain. L'autre est une vie de macérations; cela est pénible et vain. Le Tathâgata a évité ces deux extrêmes et par là, il a trouvé le Sentier du Milieu qui conduit à la clairvoyance, à la sagesse, à la tranquillité, au savoir, à la connaissance parfaite, au Nibbana . . .

— « Ce sont les Quatre Nobles Vérités :

— « Voici la Noble Vérité conernant Dukkha — souffrance —. La naissance est souffrance, la vieillesse est souffrance, la maladie est souffrance, la mort est souffrance, être uni à ce qu'on n'aime pas est souffrance ne pas réaliser son désir est souffrance . . . En résumé, les cinq éléments constituant notre être sont souffrances.

— « Voici la Noble Vérité concernant l'Origine de la souffrance — (Dukkha — Samudaya) — .C'est cette soif — Tanha — qui conduit de renaissance en renaissance, accompagnée par la convoitise et la passion, cette soif qui, ici et là, est perpétuellement en quête de satisfaction. C'est le désir de la satisfaction de la passion, la soif de la vie éternelle, de bonheur individuel dans ce monde ou dans un autre ».

— « Voici la Noble Vérité concernant la destruction de la souffrance — Dukkha Nirodha —. C'est l'annihilation entière, absolue de cette soif — Tanha — ; le rejet, la libération du désir ».

— « Voici la Noble Vérité concernant la Voie qui conduit à la destruction de la souffrance — Magga. C'est le Noble Sentier aux huit embranchements qui sont : Compréhension juste,

Pensée juste,
Parole juste,
Action juste,
Moyens d'existence justes,
Effort juste,
Attention juste,
Concentration juste.

— « C'est là, ô Bhikkhu, le Chemin du Milieu — Majjhima Patipada — que le Parfait a découvert, qui conduit au repos, à la Science, à l'Eveil, au Nibbana ». (Mahavagga du Khandhaka du Vinaya Patika).

Le Bienheureux, fixe et présise le but de son enseignement en déclarant :

— « Que vous-ai-je annoncé, ô disciples ? Ce qu'est Dukkha, ce qu'est l'origine de Dukkha, ce qu'est l'abolition de Dukkha, ce qu'est le Chemin qui mène à l'abolition de Dukkha. Voilà ce que je vous ai annoncé ». (Samyutta Nikâya).

« Ce qui sert la paix, voilà ce que je suis venu enseigner la Vérité sur la douleur (Dukkha), son origine et son extinction ». (Majjhima Nikâya).

— « De même que la grande mer, ô disciples, n'est pénétrée que d'une seule saveur, celle du sel, de même aussi, cette Doctrine et cet Ordre ne sont pénétrés que d'une seule saveur, celle de la Délivrance ». (Cullavagga du Vinaya Pitaka).

Le Bouddha Sasana est cela et rien que cela :
Une méthode de vie pour ceux qui veulent la suivre.

Mais avant d'étudier chacune des quatre nobles Vérités, il est indispensable, d'une part, de nous imprégner de l'attitude mentale que doit avoir tout bouddhiste et, d'autre

part, d'être fixés sur certaines caractéristiques fondamentales du Bouddha Sasana.

Le Bouddha Sakyamuni est le seul parmi les fondateurs de religion, à n'avoir pas prétendu être ni Dieu, ni fils de Dieu, ni une incarnation de Dieu sur terre. La seule qualité dont il se réclamait, est celle d'un être humain ayant vécu sa vie, ayant connu la vie pour la comprendre et l'apprécier à sa juste valeur. Il n'a jamais voulu être qu'un homme, qu'un maître qui enseignait et qui montrait la voie du Salut expérimentée de façon concluante en sa personne même. Aussi, tout ce qu'il a trouvé, réalisé et acquis n'est aucunement dû à des révélations divines de quelque nature que se soit ; il est le résultat de l'effort et de l'intelligence humains seuls.

C'est pour cette raison que le Bouddhisme considère comme suprême la situation humaine. L'homme est son propre maître. Au-dessus de lui, il n'y a pas d'être qui règle, qui fixe ou qui modifie sa destinée. Celle-ci est ce qu'il veut qu'elle soit ; elle n'est pas le produit de jugement d'une puissance divine. Le Tathagatta exhortait constamment ses Bhikkhus en ces termes :

— « Attahi Attano Natho » — Soyez votre propre refuge, votre propre soutien —

— « Attadipà Viharatha, attasaranà anànnasarana » (Mahaparinibbana Sutta) — Demeurez en faisant de vous-même votre île, votre refuge, ne cherchant personne d'autre pour votre refuge. Il ne cessait d'encourager, de stimuler chacun à travailler pour son émancipation en utilisant comme moyen l'effort, l'intelligence et la volonté afin de se libérer de toute servitude. Il dit :

— « Faites-vous-mêmes le travail. Les Tathagata n'enseignent que la Voie ».

Se gardant de promettre l'obtention du Salut par le truchement d'un Dieu ou des rites incantatoires, ils nous place devant notre responsabilité, il met entre nos mains notre propre pouvoir et il nous invite à n'avoir confiance qu'en nous-mêmes. A nous de suivre le chemin qu'il nous montre et si nous ne faisons rien pour y pénétrer, le parcourir et aboutir au But fixé, nul autre n'aura le pouvoir d'en assurer la réussite à notre place et en notre faveur. Les cérémonies religieuses, les prières, les vœux ne nous sont d'aucune utilité ; c'est un vite.

En vue de réaliser ce perfectionnement moral de l'homme par l'homme, afin que nous puissions triompher de nous-mêmes, de nos incalculables faiblesses, pour que naissent et se fortifient en nous les vertus, le Bouddha estimait nécessaire de laisser à chacun de ses disciples toute liberté de pensée suivant le principe de la responsabilité individuelle. C'est pourquoi il n'a jamais voulu « diriger le Sangha ni que le Sangha dépendit de lui ». Mieux, voici les conseils qu'il a donné aux Kalama quand ces derniers vinrent lui dire :

— « Seigneur, les solitaires et les brahmanes passaient à Kesaputta, exposaient et exaltaient leurs propres doctrines et condamnaient et méprisaient celles des autres. D'autres, à leur tour, tenaient les mêmes discours. Mais pour nous, nous restons toujours dans le doute et la perplexité quant à celui de ces solitaires et brâhmanes qui a exprimé la vérité et à celui qui a menti ».

Le Bienheureux leur répondit :

— « Oui, Kalama, il est juste que vous soyez dans le doute et la perplexité car le doute s'est élevé en une matière qui est douteuse. Mais écoutez, Kalama. Ne croyez pas sur la foi des traditions quoiqu'elles soient en honneur depuis de longues générations et en beaucoup d'endroits. Ne croyez pas une chose parce que beaucoup en parlent. Ne croyez

pas sur la foi des sages des temps passés. Ne croyez pas ce que vous vous imaginez pensant qu'un Dieu vous l'a inspiré. Ne vous laissez pas guider (imposer) par l'autorité des textes religieux, ni par la simple logique ou l'inférence, ni par les apparences, ni par le plaisir de spéculer sur des opinions, ni par des vraisemblances possibles.

« Mais, Kalama, lorsqu'après un examen approfondi, après avoir par vous-mêmes expérimenté, vous êtes convaincus que certaines choses sont favorables, bonnes (Kusala) et conformes à votre bien et à celui d'autrui, acceptez-les et suivez-les. Si, faisant de même, vous constatez que certaines choses sont défavorables, fausses et mauvaises (akusala) pour vous et pour les autres, alors renoncez-y ».

Cette liberté de pensée est poussée encore plus loin puisque le Bouddha n'a pas hésité un instant à inviter ses Bhikkhus à l'examiner afin qu'ils pûrent être entièrement certains de la « valeur du Maître » dont ils venaient suivre l'enseignement. Cette invitation vaut encore de nos jours. C'est là, un fait unique dans l'histoire des religions où, placés devant l'inexplicable, les tenants ont recours aux dogmes auxquels les fidèles doivent entièrement se soumettre sans autre moyen que celui de se laisser guider par une foi ou une croyance aveugle. Le Bouddha rejetait l'une comme l'autre catégoriquement parce qu'elles sont de faux moyens pour atteindre le salut, parce qu'elles font de l'homme un automate à prières. Il les condamnait comme néfaste à toute émancipation humaine vraie. Le Bouddha Sasana ne peut pas d'une soumission d'esclaves. Il veut des disciples libres dans leur examen de conscience, libres dans leur choix, libres dans leur adhésion, par la compréhension réelle de la Doctrine comme il laisse toute liberté à ceux qui estiment ne pas devoir la suivre. Pour lui, c'est VENIR VOIR, ANALYSER et COMPRENDRE et jamais VENIR CROIRE et SE SOUMETTRE.

C'est ce qui fait qu'on devient bouddhiste de façon strictement volontaire et jamais par la force ou la contrainte.

Voici quelques paroles du Bienheureux dont le sens signifie bien le rejet de foi ou de croyance aveugle :

— « Je dis, ô Bhikkhus, que la destruction des souillures et des impuretés est l'affaire d'une personne qui sait et qui voit et non d'une personne qui ne sait pas et qui ne voit pas ».

— « L'œil de la Vérité sans poussière et sans tâche – Dhamma Cakku – s'est ouvert».

— « Il a vu la Vérité, il est passé au-delà du doute, il est sans incertitude ».

— « Ainsi, avec une sagesse juste, il voit cela comme cela est – Yathà Bhùtam – (Majjhima et Samyutta Nikâya).

— « L'œil était né, la connaissance était née, la sagesse était née, la science était née ».

Ainsi, remarque-t-on que c'est toujours VOIR par la CONNAISSANCE ou la SAGESSE et jamais croire par la foi. On croit sur une affirmation et on ne peut pas dire qu'on sait. Mais dès qu'on voit, il n'y a plus de croyance et l'on peut affirmer qu'on sait.

Certes, dans les texes bouddhiques, on remontre le mot pali « Saddha » qui est traduit par « foi » ou « croyance ». Mais son sens véritable, dans le contexte où il est employé, est « une confiance née de la conviction d'où sort la dévotion à l'égard du Bouddha, du Dhamma et du Sangha ». Ce n'est rien autre et les trois aspects du mot «Saddha» définis par le grand philosophe Asanga le confirment en ces termes :

— 1°).— « Conviction entière et ferme qu'une chose est ».

— 2°).— « Joie sereine pour les bonnes qualités ».

— 3°).— « Aspiration ou souhait d'avoir la capacité d'accomplir un objet en vue ».

Le bouddhiste doit écarter de ses actes comme de sa pensée, tout esprit sectaire qui s'oppose à la tolérance et à la liberté. Il s'en suit que pour lui, toute opinion doit être respectée pour autant qu'elle n'apporte pas atteinte au bonheur d'autrui.

Nous avons vu que le Bouddha ne s'occupait que de l'enseignement des quatre Nobles Vérités. Tout ce qui ne s'y rapporte pas en est, par là, exclu. L'exemple donné par le Cùta Malunkya Sutta du Majjhima Nikâya ci-après le confirme :

— « Un de ses disciples, nommé Malunkyaputta, s'estimant insatisfait, a posé au Bouddha les questions suivantes :

— « L'univers est-il éternel ou non éternel, fini ou infini ? L'âme est-elle la même chose que le corps ou est-elle une chose et le corps une autre chose. Le Tachagata existe-t-il après la mort ou bien existe-t-il, à la fois, n'existe-t-il pas après le mort ?

Il a ajouté : « Si le Bienheureux ne connaît pas de réponses à ces questions, il est loyal de dire : « Je ne sais pas, je ne vois pas ». Alors, je quitterai l'Ordre et je m'en irai ».

Le Bouddha lui demanda :

— « T'ai-je jamais dit, Malunkyaputta, viens mener la vie sainte auprès de moi et je t'expliquerai ces questions ?

— « Non, Seigneur.

— « Alors, m'as-tu dit : « Seigneur, je viens mener la vie sainte sous sa direction et le Bienheureux m'expliquera ces questions ?

— « Non, Seigneur.

— « Et maintenant, ces conditions sont-elles posées de part et d'autre ?

— « Non, Seigneur.

— « Dans cas, sot que tu es, personne ne rejette personne (c'est-à-dire que tous deux sont libres et qu'aucun d'eux n'a d'obligations à l'égard de l'autre).

**(à suivre)**

## សហជីវិន សំ-ថាំង

ប្រែមកជាភាសាខ្មែរ ដូចមានខាងក្រោមនេះ

# ព្រះពុទ្ធសាសនា

## ការល្បងពិចារណាឲ្យយល់ជាក់

### និពន្ធដោយសម្តេចក្រុមព្រះ ស៊ីសុវត្ថិ-មុនីរ៉េត

**សូមបញ្ជាក់ថា អត្ថបទនេះសម្តេចទ្រង់បានប្រោសប្រទាន តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់ ពុ. ម. ក. ឱ្យចុះផ្សាយក្នុងទស្សនាវដ្តី ពន្លឺពុទ្ធចក្រ ដោយចុតហ្មាយលេខ ២៤១/HCT ចុះថ្ងៃទី ២១ ខែវិច្ឆិកា ១៩៦៦ ។**

យើងពិនិត្យឃើញ ទោះក្នុងខ្លួនឯងក្តី លើអ្នកដទៃដែលនៅជុំវិញយើងក្តី ថាជីវិតសឹងដល់នូវសេចក្តីសប្បាយនិងទុក្ខវេទនាជាហូរហែលាយគ្នា ជាហេតុនាំឲ្យជឿថា សេចក្តីសប្បាយនិងទុក្ខវេទនាទាំងនេះ ជាគ្រឿងនាំឲ្យមានជាតិ ជាកងប្រពាក់នៃវដ្តសង្សារ ។ យើងតែងប្រាថ្នាចង់ឲ្យជីវិតយើងជួបតែសុភមង្គលជានិច្ច ហើយចង់បន្សាត់បង់នូវសេចក្តីលំបាក នូវសេចក្តីសោកខ្សឹកខ្សួល នូវសេចក្តីចុកចាប់ទាំងឡាយដែលធ្វើជីវិតយើងឲ្យស្អាប់ស្រពោន ។ ដើម្បីឲ្យបានដូចបំណងនេះ នៅពេលថ្ងៃក្តីយប់ក្តី យើងតែងប្រព្រឹត្តនូវអំពើនានាទាំងអស់ ឲ្យតែបានដល់នូវសេចក្តីសុខ ហើយចៀសវាងសេចក្តីទុក្ខ ។ ប៉ុន្តែទោះបីយើងមានសេចក្តីព្យាយាម មានបំណង មានការបន់ស្រន់ដោយបរិកម្ម ដោយទឹកតែក្នុងពោះយ៉ាងណាក៏ដោយ មានះដែលយើងខំតាំងអធិដ្ឋានពេញកម្លាំងនោះ ពុំអាចឲ្យយើងបានដល់ពុំអាចឲ្យយើងនឹងបានដល់ដូចប្រាថ្នាបានឡើយ ។ ការណ៍នេះ ត្រូវតែទទួលដឹងដោយខ្លួនយើងដូច្នេះឯង ។

មានជនខ្លះដែលគិតឃើញថា មុខជាពុំបានសម្រេចដូចបំណងរបស់ខ្លួន ហើយដោយក្តីនឿយណាយផង ក៏ដាច់ចិត្តថា នេះជាជីវិតត្រូវតែទទួលសេចក្តីទុក្ខសុខ តាមធម្មតាទៅចុះ ។ ជនទាំងនេះគិតយ៉ាងនេះហើយ ក៏ដាច់ចិត្តស៊ូទ្រាំតាមយថាកម្មរបស់ខ្លួនទៅ គឺថាកាលណាកើតទុក្ខ ក៏បម្រះនទៀលយំសោក, កាលណាទុក្ខព្រួយចាកចេញទៅ ក៏រីករាយត្រេកត្រអាល ក្នុងក្តីសប្បាយ ដែលមានមកនោះទៅ ។ ជនជំពូកខ្លះដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភ និងប្រកបដោយសុខភាពនោះហាក់បីដូចជាកូនក្មេង ដែលសប្បាយត្រអាលភ្លេចខ្លួន មិនគិតដល់ទុក្ខព្រួយ និងសេចក្តីលំបាកទោមនស្ស ដែលអ្នកផងតែងជួបប្រទះទៅវិញ ។ ជនទាំងនេះយល់ថា ត្រូវតែខំត្រដររស់ជាមនុស្ស ។ ជនជំពូកខ្លះទៀត ដែលដល់នូវទុក្ខគ្របសង្កត់ខ្លាំងដោយវិនាសចាកបុគ្គលនិងវត្ថុជាទីស្នេហា ព្រមទាំងជួបប្រទះនឹងសេចក្តីក្រតោកយ៉ាកសព្វយ៉ាងនោះ បែរជាបន្ទន់ចិត្តបណ្តោយតាមយថាកម្ម ឬក្តៅអន្ទះអន្ទែងដោយសារវាសនាអាក្រក់ និងទុក្ខទោមនស្សដែលខ្លួនបានជួបប្រទះមកហើយនោះវិញ ។ ជនខ្លះទៀត

ដោយអស់សង្ឃឹមថា នឹងកំចាត់បង់នូវទុក្ខវេទនាបាន ឬដោយនឿយណាយក្នុងការរស់នៅជាមនុស្ស ដែលពេញទៅដោយសមុទ្រទុក្ខ ហាក់បីដូចជាឋាននរកនោះ ដាច់ចិត្តសម្លាប់ខ្លួនឯងក៏សឹងមានដែរ ។

ទុកជាជនណាប្រព្រឹត្តដូចម្ដេចក៏ដោយ, ទុកជាវឌ្ឍនភាពនៃវិទ្យាសាស្ត្រទំនើបឡើងដល់ណា ហើយនាំមកនូវសុវឌ្ឍកម្មប្រាកដប្រជា ដល់លក្ខណ៍ខាងសម្ភារៈ ក្នុងការរស់នៅរបស់មនុស្សដូចម្ដេចក្ដី ក៏វឌ្ឍនភាពនិងសុវឌ្ឍកម្មអម្បាលនោះ ពុំអាចប្រែផ្លាស់នូវសង្សារចក្រនៃជីវិត គឺជាតិ, ជរា, មរណៈ ដែលតែងតែមានសេចក្ដីសប្បាយ, មានទុក្ខតាមជាប់ប្រកិត ព្រមទាំងការថ្ងូញសោកខ្សឹកខ្សួល, សេចក្ដីទោមនស្សនិងមិនដាច់ស្រេចក្នុងចិត្តនោះបានឡើយ ។

ក្នុងការឈមមុខទល់នឹងជីវិតនៅលើផែនដី ដែលហាក់ដូចជាគេចវៀសមិនផុតនេះ ឃើញមានផ្លូវតែមួយទេ គឺមនុស្សម្នាក់ៗត្រូវជ្រើសរើសដោយខ្លួនឯងនូវតិរិយាបថ ។ បញ្ហានេះសោតសឹងមានមកតាំងពីកកើតផែនពសុធាម៉្លេះ ។

ដូច្នេះហើយ ការឆ្លើយតបនឹងបញ្ហានេះ មានតែស្វែងរកផ្លូវចេញចាកទុក្ខប៉ុណ្ណោះ ។ ដោយហេតុនេះ បានជាតាំងពីកើតផែនដីមក ផុសចេញជាលទ្ធិសាសនា ជាទស្សនវិជ្ជា ដែលសាស្ត្រាចារ្យទាំងឡាយនាំយកមកសំដែងប្រៀនប្រដៅមនុស្សបុថុជ្ជន ពីផ្លូវដែលត្រូវឲ្យប្រព្រឹត្តប្រតិបត្តិតាមនោះឯង ។ សាស្ត្រាចារ្យខ្លះរកឃើញថា ផ្លូវទៅកាន់ទីរំលត់ទុក្ខ ឋិតនៅនឹងព្រះអាទិទេពដែលជាអ្នកសម្រេចសេចក្ដីសព្វយ៉ាង ជាអ្នកជំនុំជំរះពីការខុសត្រូវ ក្នុងបាប, បុណ្យ, គុណ, ទោស ដោយយល់ថាមនុស្សលោកសុទ្ធតែកើតមកពីព្រះអាទិទេព ព្រះអាទិទេពជាអ្នកបង្កើតទឹកដី តិណជាតិ រុក្ខជាតិ និងសិលាជាតិទាំងអស់ ម៉្លោះហើយបើព្រះអង្គសព្វព្រះទ័យឲ្យល្អក៏បាន អាក្រក់ក៏បានដែរ ស្រេចលើព្រះអង្គ ។ អ្នកផងត្រូវតែឱនបន្ទន់តាមព្រះចិន្តានេះ ត្រូវតែឱនលំទោនចំពោះព្រះហឫទ័យព្រះជាម្ចាស់ ។ សុភមង្គលដ៏ស្ដើងស្ដួច ទុកជាការប្រោសប្រទានដោយសារបុណ្យកុសល ហើយឯអពមង្គលសោត ក៏ទុកជាទោសទណ្ឌដែលព្រះជាម្ចាស់សួគ៌ត្រូវឲ្យមក ទុកជាផលនៃអកុសលដែរ ដោយហេតុនេះ ដើម្បីឲ្យបាននូវសុភមង្គលហើយចៀសវាងអពមង្គល, មនុស្សត្រូវតែធ្វើពិធីការបួងសួងចំពោះព្រះអាទិទេព ដោយសារខ្លួនឯងផ្ទាល់ក្ដី ដោយពឹងរកពួកបព្វជិតក្នុងលទ្ធិសាសនាក្ដី ។ តែបើការបួងសួងទាំងនេះ ពុំបានដល់ទៅព្រះម្ចាស់ទេនោះ ក៏ឥតមានការប្រែប្រួលដែរ ។ ដូច្នេះហើយ ជីវិតរបស់អ្នកនោះ ក៏នឹងប្រព្រឹត្តទៅតាមប្រក្រតីតែក្នុងជំនឿ ដែលថាបរាជ័យកើតមកពីកំហុសរបស់ខ្លួន

តែប៉ុណ្ណោះឯង ។ ដោយសារតែមានការទមស្ការរឿយ ៗ ទៅ សេចក្ដីសង្ឃឹមមុខជានឹងកើតមានមិនទៀយ ក្នុងជីវិតរបស់មនុស្ស ។

សាស្ត្រាចារ្យដំបូងខ្លះ នាំយកវិធីធ្វើកាយនិងចិត្តឲ្យបរិសុទ្ធមកប្រដៅ ដោយតម្រូវលើអ្នកប្រតិបត្តិឲ្យបំពេញតបកម្ម ជាវត្តប្រតិបត្តិរបស់និគ្រន្ថតិរ្ថិយយ៉ាងតឹងរ៉ឹងផុតស្មើរតែកាន់តាមពុំកើត សាស្ត្រាចារ្យអស់នោះគិតឃើញថា ការប្រព្រឹត្តិវត្តបែបនេះទៅ មុខជារកផ្លូវឃើញដែរ បើមិនទាន់ដល់ទីរំលត់ទុក្ខទេគឺជំនឿបែបនេះហើយ ដែលញ៉ាំងជនដំបូងនោះ ឲ្យគាប់ចិត្តតាមគំនិតនិងអធ្យាស្រ័យរបស់ខ្លួននោះ តែថាចម្លើយបែបនេះ ក៏នៅតែដោះស្រាយបញ្ហាឲ្យជ្រះស្រឡះពុំបាន ព្រោះថាចម្លើយនេះពុំទាន់ឆ្លួនល្មម ជាចម្លើយដែលមិនទាន់ចង្អុលបុព្វហេតុនៃរោគ គឺជីវិតនេះឲ្យបានជាក់ច្បាស់ផង ទាំងជាឱសថដែលជាគ្រឿងកំចាត់រោគនេះផង ដោយផ្ដេកវេរតែទៅលើផលនៃចិត្ត ពុំបានពោលឲ្យច្បាស់ពីការពិតហើយតែតាមការដោះស្រាយដែលមានស្រាប់ផង យកតាមតែសេចក្ដីពេញចិត្ត ដោយបណ្ដោនងការធ្វើទារុណកម្មលើកាយ ដែលជាការឥតប្រយោជន៍នោះផងទៀត ។

ក្នុងសម័យនោះមានបុគ្គលមួយរូបឈ្មោះសវៃ បានរកឃើញផ្លូវតាមសេចក្ដីពិត គឺអង្គព្រះសក្យមុនីសម្ពុទ្ធនេះឯង ។ តាំងពីពេលនោះមក កន្លងទៅជាង ២.៥០០ ឆ្នាំហើយ សាសនារបស់ព្រះអង្គឥតមានវិបត្តិប្រែក្លាយដោយប្រការណាទៀយ ទោះបីពុទ្ធសាសនាបែកចេញជាលទ្ធិ, ជានិកាយច្រើនក្ដី ហាក់ដូចជាមានការប្រេះឆាយ៉ាងណាក្ដី ក៏ព្រះបរមពុទ្ធោវាទគង់នៅមានដូចកាលដែលព្រះអង្គគង់ព្រះជន្មមាននៅឡើយដែរ ។

ក្រោយដែលបានត្រាស់ដឹងនៅក្រោមដើមពោធិព្រឹក្សហើយ ព្រះសក្យមុនីសម្ពុទ្ធទ្រង់រំពឹងពិចារណា ដោយញេយ្យញាណព្រះអង្គថា ៖

— តថាគតរកឃើញធម៌ពិតយ៉ាងជ្រាលជ្រៅ, កម្រនឹងឃើញ, ពិបាកនឹងយល់ច្បាស់ ជាធម៌ដែលញ៉ាំងកាយនិងចិត្ត ឲ្យសុខក្សេមក្សាន្តជាទីប្រសើរបំផុត លើសលែងពីគំនិតបុថុជ្ជនរកឃើញហើយដែលមានតែព្រះអរិយបុគ្គលមួយទើបត្រាស់ដឹងបាន ។ នៅក្នុងព្យុះនៃវដ្ដសង្សារលើផែនពសុធានេះ មនុស្សលោកសឹងតម្រង់ទៅរកអភិជ្ឈា, ធ្លាក់ចុះទៅក្នុងវិសមលោក ដោយយល់ថាមានសេចក្ដីសប្បាយនៅក្នុងលោកយើងនេះ ។

ចំពោះមនុស្សលោកដែលត្រេកត្រអាលនៅក្នុងព្យុះនៃវាលវដ្ដសង្សារនេះ លំបាកនឹងគិតឲ្យបាន

ច្បាស់លាស់ជាងច្បាប់ដែលពោលពីសហេតុធម៌, ពីហេតុនិងបច្ច័យ ហើយជាការណ៍មួយគាន់តែលំបាក ឲ្យបានយល់ច្បាស់ដូចជាការរលត់ទៅនៃសង្ខារ, ការរលត់ទៅនៃអវិជ្ជា, ការអស់ទៅនៃកិលេស, ចិត្តបរិសុទ្ធិ គឺព្រះនិព្វានដូច្នោះដែរ ។ បើតថាគតសំដែងធម៌នេះប្រាប់ទៅហើយ គ្មានបុគ្គលណាអាច នឹងយល់ជាក់បានទេនោះ នាំតែឲ្យហត់នឿយលំបាកកាយឥតអំពើ ដល់តថាគតប៉ុណ្ណោះ ។ បើយ៉ាង នេះ តើនឹងសំដែងធម៌ដែលតថាគតខំប្រឹងព្យាយាមស្វែងរក ដោយហែលឆ្លងកាត់នូវទុក្ខអស់ពេលយូរ លង់ធ្វើអ្វីហ្ន៎, ព្រះធម៌នេះ ចំពោះមនុស្សដែលក្រាស់ដោយរាគៈនិងបដិឃៈ មានធូលីជិតជាប់នោះ មុខ ជាពុំអាចដឹងរសជាតិបានឡើយ ។ មនុស្សទាំងអម្បាលនេះសោត ដែលបណ្ដោយខ្លួនឲ្យធ្លាក់ទៅក្នុង អវិជ្ជា, ទៅក្នុងក្ដីងងឹតអន្ធការហើយនោះ មុខជាពុំអាចដើរទៅដល់សច្ចធម៌ ដែលជាគ្រឿងទំនាស់ នឹងអធ្យាស្រ័យរបស់ខ្លួន, ឯមនុស្សដែលមានសន្ដានចិត្តគ្រោតគ្រាតនោះ ក៏មិនងាយនឹងដើរឲ្យបាន ដល់ដែរ ។ ពេលនោះ ព្រះសម្ពុទ្ធទ្រង់រំពឹងដោយទិព្វញាណរបស់ព្រះអង្គ ហើយទ្រង់សំឡឹងដោយ ទិព្វចក្ខុរកមើលឧបនិស្ស័យរបស់សត្វក្នុងលោកបានទ្រង់ជ្រាបថា ៖

— ឱហ្ន៎ ! សត្វលោកហាក់បីដូចជាស្រះពេញដោយផ្កាឈូក ហើយបណ្ដាកុមុទជាតិនៅក្នុង គង្គានេះ មានឈូកខៀវ, ឈូកស ឈូកកើតក្នុងទឹក ផុសចេញពីទឹក ឈូកខ្លះដែលមិនផុតពីទឹក, ក៏ចេញផ្កាក្នុងទឹកទៅ ខ្លះទៀតលូតចេញត្រឹមផ្ទៃទឹក ហើយខ្លះទៀតលូតផុតពីទឹកក៏ចេញជាផ្កា តែឥត អង្គឹមានទទឹកជោកដល់ផ្កាសោះឡើយ ។ សេចក្ដីនេះ មានឧបមាយ៉ាងណាមិញ មានឧបមេយ្យដូច ជាមនុស្សមានចក្ខុវិញ្ញាណក្រាស់ដោយផង់ធូលី, ដូចជាមនុស្សដែលស្រួចវាងវៃ ហើយនិងមនុស្សដែល មានប្រាជ្ញាទាលទញ់តុះនោះដែរ ។ មនុស្សដែលមានសន្ដានចិត្តខ្ពង់ខ្ពស់ និងមនុស្សដែលមានសន្ដាន ចិត្តទាបថោក ។ មនុស្សងាយប្រដៅ និងមនុស្សដែលប្រដៅបានកម្រ ។ ជំពូកនេះមនុស្សទាំង អម្បាលនេះ ភាគច្រើនព្រួយបារម្ភក្នុងចិត្តទៅក្នុងលោកខាងមុខ ដោយសារតែកំហុសទម្លោយរបស់ខ្លួនៗ ដោយទ្រង់បានជ្រាបច្បាស់យ៉ាងនេះហើយ ទើបព្រះបរមសាស្ដាតាំងព្រះហឫទ័យថា ៖

— គួរតែតថាគត បើកទ្វារព្រះនិព្វានឲ្យចំហ សត្វណាដែលមានសោតប្បសាទ ចូរប្រុងផ្ទៀង ស្ដាប់ចុះ ។

— តថាគតរំពឹងឃើញដល់ភារៈដ៏ធ្ងន់ដែលត្រូវបំពេញ បានជាពុំទាន់សំដែងធម៌ទេសនា ដ៏មាន រសផ្អែមស្រទន់ និងជាគ្រឿងរំលត់បង់នូវទុក្ខស្រោចស្រង់សត្វផងទាំងពួង ។

ព្រះធម៌ដែលព្រះសម្ពុទ្ធបានទ្រង់រកឃើញនោះព្រះអង្គសំដែងថា :

ម្នាលអ្នកទាំងឡាយ ចូរអ្នកប្រុងស្ដាប់ចុះ តថាគតស្វែងរកព្រះនិព្វានឃើញហើយ បើអ្នកទាំងឡាយចរយាត្រាតាមមាគ៌ាដែលតថាគតចង្អុលប្រាប់ នោះអ្នកនឹងបានទៅដល់គោលបំណងដ៏ខ្ពង់ខ្ពស់ គឺព្រះអរហត្តផល នៅអនាគតកាលឆាប់ៗនេះមិនខាន ។ ដើម្បីដើរដល់គោលបំណងនេះ យុវៈជនក្នុងខត្តិយត្រកូលសឹងលះបង់គេហស្ថានហើយចូលកាន់ភេទជាបព្វជិត ។ ក្នុងភេទនេះអ្នកទាំងឡាយក៏នឹងត្រាស់ដឹងនូវសច្ចធម៌ ដល់នូវវិជ្ជាជាបរមត្ថ ហើយយល់ជាក់ច្បាស់ក្នុងវិជ្ជានេះដោយខ្លួនឯងផង ។

– "អន្តធម៌មានពីរប្រការ ដែលបព្វជិតទាំងឡាយគប្បីវៀរបង់ចេញឲ្យឆ្ងាយ ។ អន្តធម៌ទី១ គឺអ្នកប្រព្រឹត្តទៅក្នុងកាមភោគ និងសេចក្ដីត្រេកត្រអាល ។ កិច្ចវត្តនេះ ទុកជាគ្រឿងទាបថោក, គ្រោតគ្រាត និងឥតប្រយោជន៍ ។ អន្តធម៌ទី២ គឺការប្រព្រឹត្តិវត្តប្រតិបត្តិដោយបំពេញទុក្ករកម្ម, គឺបកម្មដល់កាយ ។ វត្តនេះជាវត្តដ៏លំបាកធ្ងន់ដោយទុក្ខវេទនា ហើយឥតប្រយោជន៍ផង ។ ព្រះតថាគតបានចៀសវាងអន្តធម៌ទាំងពីរប្រការនេះ ហើយបានរកឃើញដោយព្រះបញ្ញាញាណនូវផ្លូវកណ្ដាល ដែលដឹកនាំសត្វឲ្យបានដល់នូវទិព្វចក្ខុ ដល់ប្រាជ្ញា ដល់សេចក្ដីសុខក្សេមក្សាន្ត ដល់វិជ្ជា ដល់ការត្រាស់ដឹងនូវអនុត្តរធម៌ ដល់ព្រះនិព្វានជាទីបំផុត" ។

– "អរិយសច្ច៤ប្រការនោះគឺ ធម៌ដែលទាក់ទងនឹងទុក្ខ **ទុក្ខសច្ចៈ** នេះជាសច្ចៈ **ជាតិ** ជាទុក្ខ **ជរា** ជាទុក្ខ **ព្យាធិ** ជាទុក្ខ **មរណៈ** ជាទុក្ខ ការជួបប្រទះនឹងបុគ្គល ឬវត្ថុដែលមិនស្រឡាញ់ជាទុក្ខ, ការនិរាសចាកបុគ្គល និងវត្ថុជាទីស្រឡាញ់ជាទុក្ខ, ការមិនបានសម្រេចតាមបំណងជាទុក្ខ ។ បើពោលដោយខ្លី គឺវត្ថុធាតុទាំង ៥ ជាគ្រឿងតាក់តែងរូបកាយ ខន្ធប្រាំរបស់យើងសុទ្ធតែជាទុក្ខទាំងអស់ **រូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ**" ។

– "នេះជាសច្ចធម៌ ដែលទាក់ទងនឹងដើមកំណើតនៃទុក្ខ **ទុក្ខសមុទយៈ** គឺសេចក្ដីស្រេកឃ្លាន "តណ្ហា" ដែលនាំទៅរកជាតិ កើតស្លាប់ៗ ដោយមានវិសមលោភ, និងចបក្កិលេស តាមប្រកិតជាប់ពីខាងក្រោយស្វែងរកសេចក្ដីពេញចិត្ត គឺប្រាថ្នារកសេចក្ដីពេញចិត្ត ដើម្បីបំប៉នចបក្កិលេស, សេចក្ដីស្រេកឃ្លានចង់មានជីវិតឲ្យបានវែង, សេចក្ដីស្រេកឃ្លានចង់បានសុភមង្គលផ្ទាល់ខ្លួននៅក្នុងលោក ឬបរលោកនេះឯង" ។

– "នេះជាសច្ចធម៌ ដែលទាក់ទងនឹងការបំផ្លាញកំចាត់នូវទុក្ខ **ទុក្ខនិរោធៈ** គឺការផ្ដាច់បង់ជា សមុ-

ប្ដេទប្បហាន នូវសេចក្ដីស្រេកឃ្លាន (តណ្ហា) ការកំចាត់ចោល ការរំដោះចេញចាកពេក" ។

— "នេះជាសច្ចធម៌ ដែលទាក់ទងនឹងផ្លូវឆ្ពោះទៅរកការបំផ្លាញចោលនូវទុក្ខ **មគ្គសច្ចៈ** ជាផ្លូវដ៏ប្រសើរប្រកបដោយអង្គ ៨ ប្រការគឺ ៖

**សម្មាទិដ្ឋិ** ការយល់ត្រូវ

**សម្មាសង្កប្ប** ការត្រិះរិះត្រូវ

**សម្មាវាចា** វាចាត្រូវ

**សម្មាកម្មន្ត** ការងារត្រូវ

**សម្មាអាជីវ** ការចិញ្ចឹមជីវិតត្រូវ

**សម្មាវាយាម** ព្យាយាមត្រូវ

**សម្មាសមាធិ** សមាធិត្រូវ, ការតម្កល់ចិត្តត្រូវ ។

— ម្នាលភិក្ខុទាំងឡាយ, នេះជាផ្លូវកណ្ដាល (មជ្ឈិមាបដិបទា) ដែលព្រះអរហន្តសម្មាសម្ពុទ្ធព្រះអង្គបានរកឃើញថាជាផ្លូវសម្រាប់បើកភ្នែកនិងចិត្ត នាំឲ្យទៅដល់ទីក្សេមក្សាន្តចាកទុក្ខ ទៅដល់ការត្រាស់ដឹង, ទៅដល់ព្រះនិព្វាន (វិនយបិដកមហាវគ្គមហាខន្ធកៈ) ។

លំដាប់នោះព្រះអរហំសម្ពុទ្ធទ្រង់កំរិតនិងបញ្ចាក់ពីវត្ថុបំណងនៃធម្មទេសនារបស់ព្រះអង្គ ដោយទ្រង់ប្រកាសសេចក្ដីថា :

— ម្នាលអរិយសាវ័កទាំងឡាយ តថាគតបានសំដែងប្រាប់អ្នកពីអ្វីខ្លះ គឺពីទុក្ខ, ពីការរំលត់ទុក្ខ, ពីផ្លូវនាំឲ្យរំលត់ទុក្ខ ។ ធម៌ទាំងនេះហើយដែលតថាគតបានសំដែងប្រាប់អ្នក (សុត្តន្តបិដកសំយុត្តនិកាយ មហាវគ្គ) ។

— អ្វីៗដែលបំរើសន្តិភាពដូចតទៅនេះហើយ ដែលតថាគតនឹងប្រាប់អ្នកនោះ គឺសច្ចៈក្នុងកងទុក្ខ, ដើមកំណើត និងការរំលត់ទុក្ខ (មជ្ឈិមនិកាយ) ។

— ម្នាលភិក្ខុទាំងឡាយ, ធម៌ដែលតថាគតនឹងសំដែងប្រាប់អ្នកនោះ បីដូចជាមហាសមុទ្រដែលមានរសជាតិប្រៃតែម្យ៉ាង គឺជាតិអំបិលយ៉ាងណាមិញ ព្រះធម៌នេះឯងក៏មានតែការចេញចាកទុក្ខដូច្នេះដែរ (សុត្តន្តបិដក មជ្ឈិមនិកាយ) ។

ពុទ្ធសាសនា មានត្រឹមតែប៉ុណ្ណោះ គឺវិធីសម្រាប់ជីវិតចំពោះបុគ្គលដែលប្រតិបត្តិតាម (វិនយបិដក ចុល្លវគ្គ) ។

មុននឹងសិក្សាពីអរិយសច្ចទាំងបួនប្រការ (ចតុរារិយសច្ចៈ) នោះ គួរតែយើងត្រិះរិះពិចារណា ពីអាកប្បកិរិយាតាមផ្លូវចិត្ត ដែលពុទ្ធសាសនិកត្រូវមានសិន ហើយនឹងត្រូវកំណត់ក្នុងចិត្តឲ្យជាក់ច្បាស់ពីលក្ខណៈជាមូលគ្រឹះនៃពុទ្ធសាសនាទៀតផង ។

ព្រះសក្យមុនី ជាសាស្ដាឯកក្នុងលោក ក្នុងចំណោមអ្នកបង្កើតលទ្ធិសាសនា ដែលពុំបានទុកព្រះអង្គជាព្រះអាទិទេព, ជាបុត្ររបស់ព្រះអាទិទេព ទាំងពុំមែនជាអវតារនៃព្រះម្ចាស់សួគ៌ នៅលើផែនដីទៀតផង ។ គុណធម៌តែមួយដែលទ្រង់ប្រកាន់យកនិងទុកដាក់ព្រះអង្គ គឺជាគុណសម្បត្តិរបស់មនុស្ស ដែលធ្លាប់បានរស់នៅជាមនុស្សច្រើនជាតិ, ធ្លាប់បានស្គាល់គុណ និងទោសនៃកំណើតមនុស្ស ហើយបេះធ្មើមូលវិចារទៅតាមសេចក្ដីពិតប៉ុណ្ណោះឯង ។ ព្រះអង្គមានតែព្រះបំណងជាមនុស្ស ជាគ្រូអាចារ្យប្រៀនប្រដៅ និងជាអ្នកបង្ហាញផ្លូវសត្វទៅកាន់ឋានរំលត់ទុក្ខ ដែលព្រះអង្គទ្រង់បានពិសោធ ហើយជ្រាបច្បាស់ចំពោះព្រះអង្គឯងប៉ុណ្ណោះ ។ ដូច្នេះព្រះធម៌ដែលទ្រង់រកឃើញនោះ ពុំមែនដោយសារឃោសនារបស់ទេវតាអង្គណាឥតអង្គីមានដែរ គឺជាលទ្ធផលនៃសេចក្ដីព្យាយាម និងប្រាជ្ញាញាណរបស់មនុស្សតែប៉ុណ្ណោះ ។

ដោយហេតុនេះ បានជាពុទ្ធសាសនាចាត់ទុកស្ថានភាពមនុស្ស ថាជាទីខ្ពង់ខ្ពស់បំផុតនោះឯង ។ មនុស្សជាគ្រូអាចារ្យរបស់ខ្លួន ។ នៅពីលើមនុស្សឥតមានបុគ្គលដទៃ ជាអ្នកសម្រេច ជាអ្នកកំណត់ ជាអ្នកកែបំបែរនូវវាសនារបស់មនុស្សបានឡើយ ។ វាសនានៃមនុស្សផ្អែកទៅតាមយថាកម្មរបស់ខ្លួន ពុំមែនជាផលកើតចេញពីការវិនិច្ឆ័យរបស់ទេវតាអ្នកមានមហិទ្ធិឫទ្ធិអង្គណាមួយឡើយ ។

ព្រះតថាគត ដែលបានទ្រង់ដាស់តឿនទូន្មានភិក្ខុសង្ឃរឿយៗជាអនេកប្បការដូចតទៅ :

**«អត្តាហិ អត្តនោ នាថោ»** អ្នកទាំងឡាយចូរយកខ្លួនជាទីពឹងពំនាក់របស់ខ្លួនឯងចុះ ។

**«អត្តទីបា វិហរថ អត្តសរណា អនញ្ញសរណា»** (មហាបរិនិព្វានសូត្រ) អ្នកទាំងឡាយចូរធ្វើខ្លួនឯងជាកោះ ជាជម្រកចុះ កុំគប្បីរកអ្នកដទៃក្រៅពីអាត្មាឯង មកជាជម្រកឡើយ ។ ព្រះបរម-គ្រូព្រះអង្គតែងតែលើកទឹកចិត្ត, តែងតែជម្រុញចិត្តពុទ្ធបរិស័ទរៀងរាល់អាត្មាឲ្យខំប្រឹងប្រព្រឹត្តខ្លួន ដើម្បីចេញចាកសង្សារទុក្ខ ដោយយកវីរិយៈ, ប្រាជ្ញានិងឆន្ទៈជាមធ្យោបាយប្រើ ដើម្បីកំចាត់បង់នូវទោសៈ

នៃតណ្ហា ទើបទ្រង់មានព្រះពុទ្ធដីកាថា ៖

– "អ្នកទាំងឡាយ ចូរបំពេញវត្តប្រតិបត្តិដោយខ្លួនឯងចុះ តថាគតគ្រាន់តែជាអ្នកបង្ហាញផ្លូវដល់អ្នកទេ" ។

ព្រះសម្ពុទ្ធពុំបានសន្យាក៏ប៉ុន្តែថា ការចេញចាកទុក្ខនឹងកើតបានដោយសារគុណានុភាព នៃព្រះម្ចាស់សួគ៌ ឬដោយពិធីបួងសួងដទៃឡើយ ព្រះអង្គទុកឲ្យទទួលខុសត្រូវដោយខ្លួនឯង ព្រះអង្គទុកអំណាចឲ្យនៅក្នុងកណ្ដាប់ដៃរបស់យើងទាំងអស់ ហើយទ្រង់ប្រៀនប្រដៅយើងឲ្យផ្ញើទំនុកទុកចិត្តតែលើខ្លួនឯងមួយ ។ ដូច្នេះត្រូវយើងចរគ្រាប់តាមផ្លូវដែលព្រះអង្គចង្អុលប្រាប់ ហើយបើយើងឥតវល់ទីងប្រព្រឹត្ត ដើម្បីឲ្យបានចូលទៅកាន់ផ្លូវនោះទេ ឥតមានជនដទៃក្រៅណាមួយនឹងមានអំណាចក៏ប៉ុន្តែឲ្យបានសម្រេចតាមបំណងរបស់យើងជាជំនួសខ្លួន ឬ ជាកិច្ចអនុគ្រោះដល់យើងសោះឡើយ ។ ពិធីទាំងឡាយតាមគន្លងសាសនាក្ដី ការសូត្រធម៌ក្ដី ការបន់ស្រន់បួងសួងក្ដី ទាំងអស់នេះ សុទ្ធតែឥតមានប្រយោជន៍ដល់យើងទេ គឺជាការអសារសូន្យទាំងអស់ ។

ដើម្បីឲ្យបានសម្រេចនូវវិសិដ្ឋការខាងផ្លូវចិត្តរបស់មនុស្ស ដោយមនុស្សខ្លួនឯងក្ដី ដើម្បីអាចឲ្យខ្លួនយើងឈ្នះខ្លួនយើង, ឈ្នះលើការទន់ខ្សោយជាអនេកប្បការ ហើយញុំាងគុណធម៌ទាំងឡាយឲ្យកើតមានរឹងប៉ឹងឡើង ព្រះបរមគ្រូទ្រង់ឈ្វេងយល់ថា "ត្រូវតែបើកឲ្យសាវ័ករបស់ព្រះអង្គមានសេរីភាពក្នុងការពិចារណាតាមគោលការណ៍ស្ដីពីការទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗ ដោយហេតុនេះ បានជាទ្រង់ពុំព្រមធ្វើជាអ្នកនាំព្រះសង្ឃ ឬទុកព្រះសង្ឃឲ្យនៅក្រោមឱវាទរបស់ព្រះអង្គនោះឯង ។

ខាងក្រោយនេះ ជាពុទ្ធតម្រាស់ប្រារព្ធដល់កាលាមជន កាលដែលពួកនេះចូលទៅក្រាបបង្គំទូលសួរព្រះអង្គថា :

– "បពិត្រព្រះបរមគ្រូដ៏ចំរើន ពួកតាបសឫសី និងព្រាហ្មណ៍ដែលបានមកដល់កេសបុត្តនេះបានថ្លែងនិងអួតសរសើរពីលទ្ធិរបស់ខ្លួន ហើយទុកដាក់នឹងប្រមាថមើលងាយលទ្ធិធម៌របស់អ្នកដទៃ ។ ពួកខ្លះទៀតក៏បានបរិហារដូច្នេះដែរ ។ ខ្ញុំព្រះអង្គនៅតែមានក្ដីសង្ស័យមិនអស់ពីក្នុងចិត្ត ពុំដឹងជាពួកតាបសឫសី និងព្រាហ្មណ៍ទាំងនោះណាមួយពោលតាមសច្ចធម៌ ណាមួយកុហកយើង ។

លំដាប់នោះព្រះអរហន្តសម្ពុទ្ធទ្រង់តបថា :

– ម្នាលកាលាមជន, ពិតមែនហើយដែលអ្នកទាំងឡាយនៅមានសង្ស័យ នៅមានអល់ឯកមិន

អស់អញ្ជនោះ ព្រោះថា សង្ស័យកើតមានក្នុងរឿងដែលគួរឲ្យសង្ស័យ ប៉ុន្តែឲ្យអ្នកទាំងឡាយជឿងសោត-ប្បសាទចាំស្តាប់ចុះដូចតទៅនេះ ៖

១– កុំប្រកាន់ជឿដោយឮស្តាប់តាមគ្នា

២– កុំប្រកាន់ជឿដោយឃើញថាជារបស់បរមបូរាណ

៣– កុំប្រកាន់ជឿដោយដំណឹងថា យ៉ាងនេះ ៗ

៤– កុំប្រកាន់ជឿដោយអាងគម្រោ...

៥– កុំប្រកាន់ជឿដោយនឹកស្មានយកខ្លួនឯង (តក្កវិជ្ជា ឬសេចក្តីសន្និដ្ឋាន)

៦– កុំប្រកាន់ជឿដោយន័យដៅយកតាមគម្រោងការខាងក្រៅ

៧– កុំប្រកាន់ជឿដោយនឹកគិតតាមអាការៈ

៨– កុំប្រកាន់ជឿដោយចូលចិត្តថា ត្រូវនឹងលទ្ធិរបស់ខ្លួន

៩– កុំប្រកាន់ជឿថានិយាយសមគួរនឹងជឿ

១០– កុំប្រកាន់ជឿដោយគប់អានថាសមណៈនេះជាគ្រូរបស់យើង ៗ

(សុត្តន្តបិដក អង្គុត្តរនិកាយតិកនិបាតកាលាមសូត្រ)

– តើថាបើអ្នកទាំងឡាយ បានពិចារណា យ៉ាងល្អិតល្អន់, បានធ្វើការពិសោធទៅហើយ យល់ឃើញថាល្អត្រឹមត្រូវ, ថាជាបុណ្យជាកុសលនាំមកនូវសេចក្តីសុខ . ចំរើនដល់អ្នកនិងជនដទៃនោះ អ្នកទាំងឡាយគប្បីទទួលជឿ ហើយយកទុកជាវត្តប្រតិបត្តិទៅចុះ ៗ បើអ្នកត្រិះរិះពិចារណាទៅឃើញថាជាគ្រឿងផ្ទុយនឹងបុណ្យកុសល ដើម្បីខ្លួនអ្នកនិងជនដទៃនោះ ត្រូវតែលះបង់ចោលឲ្យស្រឡះពីខន្ធសន្តានរបស់អ្នក ៗ

សេរីភាពក្នុងការត្រិះរិះពិចារណា បែបនេះ កាន់តែមានឆ្ងាយទៅទៀត ដោយហេតុថាព្រះពុទ្ធជាម្ចាស់ ពុំដែលទ្រង់ញាញើតនឹងជាស់តឿនកិក្ខុសង្ឃ ដែលប្រតិបត្តិតាមពុទ្ធោវាទឲ្យប្រព្រឹត្ត យ៉ាងនេះ ដើម្បីឲ្យបានជាក់ច្បាស់ក្នុងតម្លៃនៃព្រះអង្គឡើយ ៗ ពុទ្ធតម្រាស់ក្រើនរំលឹកនេះ នៅតែមានតម្លៃដល់បច្ចុប្បន្នកាលដដែល ៗ ការណ៍នេះជាដំណើរតែមួយគត់ក្នុងប្រវត្តិនៃលទ្ធិសាសនាទាំងឡាយ ដែលបរិស័ទជាអ្នកកាន់ដើងទាល់គំនិតធ្វើយដោះស្រាយមិនរួចនឹងពាក្យសួរដណ្តឹង ហើយបែរជាយកសិទ្ធានុក្នុងលទ្ធិនោះមកធ្វើជាសំអាងក្នុងការដោះស្រាយដោយប្រាប់ពន្យល់ថា ត្រូវតែគោរពជឿឥតមានថ្ងៃ

ណាមួយគេចចៀស ក្រៅពីបណ្ដោយគំនិតទៅក្នុងជំនឿដ៏ងងឹតងងល់សោះឡើយ ។ ព្រះពុទ្ធជាម្ចាស់បានទ្រង់កាត់ចោលការដោះស្រាយបែបនេះទាំងអស់ ដោយទ្រង់ជ្រាបច្បាស់ថា ពុំមែនជាផ្លូវដ៏ប្រសើរសម្រាប់ឲ្យដើរទៅដល់ទីរំលត់ទុក្ខ គឺជាផ្លូវដឹកនាំមនុស្សឲ្យទៅជាយន្តតក្កតា ក្នុងពិធីសូត្រធម៌បួងសួងតែប៉ុណ្ណោះឯង ។ ព្រះបរមគ្រូទ្រង់បានចាត់ទុកមធ្យោបាយទាំងនោះ ថាជាគ្រឿងប្រទូស្តនឹងការចេញចាកទុក្ខពិតៗនៃមនុស្ស ។ ព្រះពុទ្ធសាសនាឥតមានបំណងឲ្យបរិស័ទជឿតាម បីដូចជាទាសៈទេ គឺចង់ឲ្យបរិស័ទមានសេរីភាពក្នុងការត្រិះរិះពិចារណា តាមមនសិការរបស់ខ្លួន មានសេរីភាពក្នុងការជ្រើសរើស, មានសេរីភាពក្នុងសច្ចកម្ម ដោយបានយល់ជាក់ក្នុងពាក្យប្រៀនប្រដៅ ។ ដំណើរនេះដូចគ្នានឹងការដែលព្រះអង្គទុកសេរីភាពឲ្យជនដែលមិនជឿ ហើយយល់ថាមិនត្រូវប្រតិបត្តិតាមនោះដែរ ។ ព្រះសម្ពុទ្ធមានតែទ្រង់ត្រាស់ហៅបរិស័ទឲ្យចូលមកមើល, ពិនិត្យសង្កេតឲ្យយល់ជាក់ដោយខ្លួនឯង ពុំមែនឲ្យជឿ ហើយគោរពឱនលំទោននោះឡើយ ។

តាមន័យនេះ ឃើញថាអ្នកផងទៅជាពុទ្ធសាសនិក តាមសេចក្ដីស្មោះស្ម័គ្ររបស់ខ្លួន ពុំដែលមានដោយសារការកម្ហាំងដល់ម្ដងណាទេ ។

សេចក្ដីខាងក្រោយនេះ ជាពុទ្ធតម្រាស់របស់ព្រះអរហន្តសម្ពុទ្ធមានន័យថាត្រូវកាត់ចោល នូវសទ្ធាឬជំនឿដោយងងឹតងងល់ ។

– ម្នាលភិក្ខុទាំងឡាយ តថាគតបានប្រាប់អ្នកថា ការកំចាត់បង់នូវសេចក្ដីបរិសុទ្ធិ និងមិនបរិសុទ្ធិស្រេចតែលើបុគ្គលម្នាក់ៗ ដែលចេះហើយឃើញច្បាស់ទេ មិនគឺស្រេចលើបុគ្គលដែលមិនចេះ និងមិនឃើញច្បាស់ក្នុងព្រះធម៌នោះសោះឡើយ ។

– សោតៈរបស់បុគ្គលដែលមានធូលីគឺកកៈទៅប្រាសហើយ ធម្មចក្ខុក៏បើកផ្លូវឲ្យឃើញច្បាស់ដែរ បុគ្គលនោះបានឃើញសច្ចធម៌លែងមានវិចិកិច្ឆា លែងមានការមិនដាច់ស្រេចក្នុងចិត្តទៀតហើយ ។

– ដោយហេតុផលនូវបញ្ញាជាលោកុត្តរ បុគ្គលនោះក៏ឃើញច្បាស់នូវសច្ចធម៌ជាយថាភូត(មជ្ឈិម-និកាយនិងសំយុត្តនិកាយ) ។

– ចក្ខុកើតហើយ, ញាណកើតហើយ, បញ្ញាកើតហើយ, វិជ្ជាកើតហើយ, ពន្លឺកើតហើយ ។

ដោយហេតុនេះ គេសំគាល់ឃើញថាត្រូវតែឃើញដោយញាណ ឬបញ្ញាជាដរាប ពុំដែលឮថាព្រះបរមគ្រូឲ្យជឿដោយអធិមោក្ខដល់ម្ដងណាឡើយ ។ បើគេជឿតាមតែសេចក្ដីអះអាងគេពុំអាចថា